# ព្រះនគរ
# PREAH NOKOR
## Journal of Angkor Studies

លេខ ១, ឆ្នាំ២០១៩ / Number 1, 2019 / Numéro 1, 2019



អាជ្ញាធរអប្សរា
APSARA

# PREAH NOKOR
## Journal of Angkor Studies


បោះពុម្ពផ្សាយប្រចាំឆ្នាំដោយអាជ្ញាធរជាតិអប្សរា

Published annually by The APSARA National Authority

លេខ ១, ឆ្នាំ២០១៩ / Number 1, 2019 / Numéro 1, 2019

សៀមរាប / Siem Reap

អាជ្ញាធរជាតិអប្សរា

APSARA National Authority

PREAH NOKOR
Journal of Angkor Studies

ចេញផ្សាយប្រចាំឆ្នាំដោយអាជ្ញាធរជាតិអប្សរា
Published annually by The APSARA National Authority

និពន្ធនាយក / Editor
ត័ន ប៊ុនស៊ុយ / Tan Bunsuy, *Former Deputy Director, APSARA National Authority*

គណកម្មការពិនិត្យ / Editorial Board
គឹម សំណាង / Kim Samnang, *APSARA National Authority*
ទិន ទីណា / Tin Tina, *APSARA National Authority*
លី វណ្ណា / Ly Vanna, *APSARA National Authority*
ហង់ ពៅ / Hang Peou, *APSARA National Authority*
អ៊ា ដារិទ្ធ / Ea Darith, *APSARA National Authority*
អ៊ុម សុខរិទ្ធី / Im Sokrithy, *APSARA National Authority*
អាំង ជូលាន / Ang Chouléan, *Advisor, APSARA National Authority*

អ្នកគ្រប់គ្រងបច្ចេកទេស / Technical Manager
គឹម សំណាង / Kim Samnang, *APSARA National Authority*

លេខទី១, ២០១៩ / Volume 1, 2019
ចេញផ្សាយប្រចាំឆ្នាំដោយអាជ្ញាធរជាតិអប្សរា
សៀមរាប, ព្រះរាជាណាចក្រកម្ពុជា
COPYRIGHT © 2019 by Preah Nokor, *All Rights Reserved*
ISBN: 9-789924-939405

9 789924 939405 >

# មាតិកា / Contents


*បុព្វបទ* ....................................................................................................iii

បុរាណវត្ថុរកឃើញថ្មីៗនៅអង្គរ....................................................................1
*ភឹង តារា, ឈូក សូម៉ាឡា, សាន កុសល, គឹម សេងភក្តី, ឡេ ពិសី,*
*សៀង សុផានី, ស៊ីថា វិសារទបុត្រ, អេង រីណា និង ផន សុវិបុល*

Angkor as a Cultural Continuum..........................................................................25
*Sachchidanand Sahai*

ការអភិរក្ស ជួសជុលប៉មឥដ្ឋលេខ៨នៅប្រាសាទ ចាកង.............................................33
*តាន់ សុផល*

Preliminary Research on the Royal Palace Bronze Workshop of Angkor Thom........................49
*Martin Polkinghorne and Brice Vincent*

The Microstructure and 2D-Element Analysis of Sandstone in Angkor..................................63
*K. Kranda and V. Havránek*

From Aerial Photos to Lidar: New Developments in the Mapping of Angkorian Sites.............69
*Damian EVANS, TAN Boun Suy, HENG Kamsan*

ឡើងអ្នកតាខែពិសាខនៅវត្តអធ្វា .........................................................................79
*អ៊ូ គង្គា*

Deconstructing a Reconstruction at Angkor......................................................................91
*Christophe Pottier*

Numerical Simulations of Static Behaviour of Stone Temples in Angkor.................................103
*Jan Pasek, Hansley Pravin Gaya and Karel Kranda*

ប្រព័ន្ធធារាសាស្ត្រនៃឧទ្យានអង្គរ ...................................................................113
*ហង់ ពៅ*

ប្រព័ន្ធធារាសាស្ត្រនៃប្រាសាទព្រះវិហារ .............................................................121
*ហង់ ពៅ*

# បុព្វបទ

*នេះជាលើកទីមួយហើយ ដែលអាជ្ញាធរអប្សរាចេញផ្សព្វផ្សាយនូវទស្សនាវដ្តីមួយដែលអត្ថបទទាំងអស់កើតឡើងពីការស្រាវជ្រាវ មានន័យថាពុំមែនស្ថិតនៅក្នុងប្រភេទសំណេរឃោសនា ដ្បិតគោលបំណងធំគឺពុំមែននិយាយពីអាជ្ញាធរយើងខ្លួនឯងឡើយតែគឺដើម្បីនិយាយពីអតីតរាជធានីយសោធរពោលគឺ ព្រះនគរ របស់ខ្មែរទាំងអស់។*

*អត្ថបទខ្លះតាក់តែងឡើងពីសំណាក់អ្នកស្រាវជ្រាវជាតិ ខ្លះទៀតពីអន្តរជាតិ។ រីឯប្រភេទប្រធានបទវិញក៏មានច្រើនបែប គឺថាមានអត្ថបទជាការពិចារណាទូទៅលើការវិវឌ្ឍន៍នៃរាជធានីអង្គរ, មួយចំនួនមានលក្ខណៈជាបច្ចេកទេស ដូចជាការលម្អិតផែនទីបុរាណស្ថានឲ្យកាន់តែជ្រៅជ្រះ ដោយយោងតាមទិន្នន័យថ្មីៗមកទៀតដែលបានមកពីរូបពីលើអាកាសហៅថា LiDAR, ការសិក្សាពិនិត្យសមាសធាតុនៃថ្មដែលខ្មែរបុរាណយកមកសាងប្រាសាទ, រោងជាងសិតសម្រិតនៅព្រះរាជវាំងអង្គរធំ។ អត្ថបទខ្លះជាបច្ចេកទេសដែរ តែទាក់ទងនឹងការថែទាំព្រមទាំងការជួសជុលដូចជា ការថែទាំទប់ចម្លាក់ថ្មកក់និងចម្លាក់បាយអកុំឲ្យវិចរិលតទៅទៀត ដោយឆ្លងតាមបទពិសោធន៍ច្រើនឆ្នាំមកហើយនៅអង្គរ, ការជួសជុលសំណង់ធ្វើពីឥដ្ឋ។ មានអត្ថបទមួយបង្ហាញឲ្យអ្នកអានជ្រាបអំពីវត្ថុបុរាណប្រភេទច្រើនបែបយ៉ាងដែលអាជ្ញាធរយើងបានប្រទះឃើញនៅទីនានា ហើយបានយកមករៀបចំទុកដាក់កត់ត្រាជាបញ្ជីសារពើភ័ណ្ឌ។ អត្ថបទក្នុងពពួកនរវិទ្យាក៏មានដែរក្នុងលេខនេះមាននិយាយអំពីបុណ្យទាក់ទងនឹងស្រូវ ដែលអ្នកស្រុកប្រារព្ធនៅក្នុងបុរាណស្ថាន ដោយសារទីនោះជាទីសក្ការៈរបស់គាត់។ ឯក្នុងវិស័យជាភាសាស្ត្រវិញ លេខដំបូងនេះមានការសិក្សាពីរ។ មួយស្តីអំពីតំបន់អង្គរ មួយទៀតទាក់ទងនឹងប្រាសាទព្រះវិហារ។*

*យើងសង្ឃឹមថាអ្នកអាននឹងមានការរីករាយក្នុងការទទួលពត៌មានដែលជាចំណេះដឹងអំពីអតីតកាលផង នឹងស្ថានភាពនៃ ព្រះនគរ យើងនាបច្ចុប្បន្ននេះផង។*

*ហង់ ពៅ*
*អគ្គនាយក*

# បុរាណវត្ថុរកឃើញថ្មីៗនៅអង្គរ

*ភឹង តារា, ឈូក សូម៉ាឡា, សាន កុសល, គឹម សេងភក្ដី, ឡេ ពិសី*
*សៀង សុផានី, ស៊ីថា វិសារទបុត្រ, អេង រីណា និង ផន សុរិបុល**
*អាជ្ញាធរជាតិអប្សរា*

*តំបន់អង្គរ និយាយក្នុងន័យទូលំទូលាយ ក្លាយមកជាមណ្ឌលធំបង្អស់នៃអាណាចក្រខ្មែរនៅស.វ.ទី៩ ហើយស្ថិតនៅជារាជធានីរហូតដល់ស.វ.ទី១៥។ ប៉ុន្តែមុននោះទៅទៀតក៏មនុស្សមកតាំងទីជាយូរយាមកហើយ។ គេមិនត្រឹមតែប្រទះឃើញប្រាសាទ និងសំណង់ផ្សេងៗសាងនៅស.វ.ទី៧-៨ប៉ុណ្ណោះទេ ប៉ុន្តែគឺមានស្ថានីយ៍បុរេ-ប្រវត្តិជាច្រើនទៀតផង។ គិតតែប៉ុណ្ណោះទៅ យើងអាចយល់ហើយថាតើចំនួនបុរាណវត្ថុដែលនៅសេសសល់មានច្រើនលើសលុបដល់ត្រឹមណា។ នៅជំនាន់អាណានិគមបារាំង គេបានធ្វើការស្រាវជ្រាវនិងរៀបចំជួសជុលព្រមទាំងរក្សាទុកនូវវត្ថុជាច្រើន។ តពីនោះមកក៏ការងារទាំងនោះនៅតែបន្ត។ ការងារនេះនៅទ្រឹងក្នុងពេលសង្គ្រាមនិងក្រោយសង្គ្រាមនាទសវត្សរ៍១៩៧០-៨០ បន្តិចមែន តែបន្ទាប់មកគេក៏ងាកមករៀបចំការថែរទាំនិងលើកតម្លៃដូចមុនវិញដែរ។ ក្នុងទេសកាលថ្មីនេះ រាជរដ្ឋាភិបាលបានបង្កើតអាជ្ញាធរអប្សរាដើម្បីបំពេញនាទីនេះក្នុងក្របខណ្ឌនៃកាតព្វកិច្ចមួយធំធេងលើសនេះទៅទៀត។ អត្ថបទនេះនិយាយតែពីការប្រទះឃើញនូវបុរាណវត្ថុនាពេលថ្មីៗកន្លងមកតែប៉ុណ្ណោះ។*

*តាំងពីឆ្នាំ២០០៨រហូតមកទល់ពេលនេះ មានបុរាណវត្ថុចំនួនជាង៦៧០រូប ដែលភាគច្រើនធ្វើអំពីថ្មភក់ លោហៈ (មាស ដែក សំណ សំរិត) និងឈើ។ បុរាណវត្ថុទាំងអស់នោះបានចុះក្នុងបញ្ជីសារពើភណ្ឌលម្អិតរួចហើយ។ ប៉ុន្តែនៅក្នុងអត្ថបទនេះ វត្ថុណាដែលមានច្រើន តែដែលមានរូបរាងកិនភាគប្រហាក់ប្រហែលគ្នា យើងមិនយកមកបង្ហាញទាំងអស់ឡើយ គឺយើងគ្រាន់តែជ្រើសរើសរូបណាមួយដែលអាចទុកជាតំណាងឲ្យក្រុមទាំងមូលបាន។ ចំពោះវត្ថុដែលពុំអាចបញ្ចូលទៅក្រុមណាមួយ យើងយកមកបង្ហាញជាស្វ័យប្រវត្តិ។ ទាំងអស់នេះយើងបង្ហាញរូបដោយគ្រាន់តែមានបរិយាយខ្លីៗតែប៉ុណ្ណោះ។ ឯរូបខ្លះៗទៀតដែលយើងយល់ថាមានសារសំខាន់ដោយសារពុំធ្លាប់ឃើញពីមុនៗមក យើងព្យាយាមបរិយាយឲ្យបានក្បោះក្បាយ។ សូមបញ្ជាក់*

* *ក្រុមចុះបញ្ជីសមុច្ច័យបុរាណវិទ្យា, នាយដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ។*

ថាបុរាណវត្ថុដែលរកឃើញក្នុងតំបន់អង្គរ ភាគច្រើនបានមកពីកំណាយក្នុងការដ្ឋាននានានៃស្ថាប័នអភិរក្ស និងស្រាវជ្រាវជាតិនិងអន្តរជាតិ ប៉ុន្តែមួយភាគទៀតបានមកពីការប្រទះឃើញដោយចៃដន្យពីសំណាក់ប្រជាជន និងតាមកត្តាធម្មជាតិផ្សេងទៀតដូចជាដើមឈើរលំបណ្ដាលឲ្យវត្ថុខ្លះផុសចេញមកពីដី។ តទៅនេះយើងសូមបង្ហាញរូបមួយចំនួនតាមលក្ខណៈដែលពោលមកអម្បាញ់មិញនេះ។



រូបលេខ១

## ១. ប្រាសាទតាព្រហ្ម

ក្នុងចំណោមរូបចម្លាក់ដែលរកឃើញ មានរូបចម្លាក់ជាច្រើនបានពីប្រាសាទតាព្រហ្ម។ ប្រាសាទនេះ អ្នកសិក្សាតំបន់អង្គរតែងដឹងគ្រប់គ្នាហើយថា ពីមុនមកពុំដែលមានការជួសជុលអ្វីឡើយ។ មូលហេតុនោះគឺ មានប្រាសាទមួយចំនួននៅតំបន់អង្គរដែលមានភិនភាគប្រហាក់ប្រហែលគ្នា ដូចជាប្រាសាទព្រះខ័ន និង បន្ទាយក្ដីជាដើម។ ម្យ៉ាងទៀតបើនិយាយពីប្រាសាទដែលសាងជំនាន់គ្នា ហើយរចនាបថដូចគ្នានោះគឺមាន តែច្រើនជាងនេះទៅទៀត។ ដូច្នេះអ្នកគ្រប់គ្រងអភិរក្សអង្គរជំនាន់មុន ដែលបានជួសជុលប្រាសាទទាំង អម្បាលម៉ាននោះយល់ថាគួរទុកប្រាសាទតាព្រហ្មឲ្យស្ថិតនៅក្នុង សភាពបាក់បែក ហើយមានដើមឈើធំៗ ជាពិសេសដើមស្ពង់ដែលតែងមានឫសជ្រែកលើជញ្ជាំងឬ កំពូលប្រាង្គនានានោះសិនចុះ ទុកឲ្យអ្នកទស្សនា មានអារម្មណ៍ថាខ្លួនស្ថិតនៅក្នុងបរិយាកាសឬពេល មួយផ្សេង ឧទាហរណ៍នៅស.វ.ទី១៩ឬក៏ដើមស.វ.ទី២០ ដែលយូរៗម្ដងមានមនុស្សទៅទស្សនាដល់ទីនោះ។គំនិតទូទៅនេះប្ដូរផ្ទាស់ហើយគឺអាជ្ញាធរអប្សរាដែលមាន

តួនាទីគ្រប់គ្រងរមនីយដ្ឋានអង្គរយល់ថាមិនអាចទុកក្នុងសភាពនេះតទៅទៀតទេ  ល្មមដល់ពេលវេលាត្រូវរៀបចំឲ្យទស្សនិកជន ដើរចេញចូលពិនិត្យបានស្រួលបួលហើយ។ កាលពីចុងឆ្នាំ២០១២ មានដើមស្ពង់មួយដើមបាក់រលំមកដីមែន ជាការបង្ហាញថាបើទុកឲ្យប្រាសាទនេះស្ថិតក្នុងសភាពដដែល ច្បាស់ជានឹងមានការខូចខាតតទៅទៀត។ ការជុសជុលក្នុងកម្មវិធីស្តារស្រោចស្រង់ទាំងមូលនេះ ធ្វើ ឡើងដោយសហការជាមួយក្រុមអ្នកឯកទេសឥណ្ឌានៃស្ថាប័ន Archaeological Survey of India ( ASI )។តទៅនេះ យើងសូមបង្ហាញរូបខ្លះៗដែលប្រទះឃើញក្រោយពីដើមស្ពង់មួយដើមរលំដួលដោយភ្លៀងធ្លាក់ (រូបលេខ២១) ។



រូបលេខ២២



រូបលេខ២៣



រូបលេខ២៤



រូបលេខ២៥

## ១.២. ព្រះបរមរូបព្រះបាទជ័យវរ្ម័នទី៧

ចម្លាក់មួយដែលធ្វើឲ្យគេមានការចាប់អារម្មណ៍ខ្លាំងជារូបបុរសម្នាក់មានមាឌធំស្លៀកសំពត់ចងក្បិនខើចត្រឹមភ្លៅ លែងខ្លួនទទេអង្គុយពែនភ្នែន សក់ស្លូតបួងជាផ្នួងតូចនៅលើក្បាល ភ្នែកទាំងពីរបិទ ទឹកមុខស្ងប់ឱនក្បាលចុះបន្តិច ក្នុងឥរិយាបថសមាធិ។ រូបប្រហាក់ប្រហែលនឹងរូបនេះ គេធ្លាប់ឃើញនៅទីផ្សេងៗទៀត

ដែលមានការសិក្សាជាហូរហែរចំណោមអ្នកស្រាវជ្រាវធំៗជាពិសេសលោកGeorge Cœdès។ការសិក្សាទាំងនោះធ្វើឲ្យគេសន្និដ្ឋានថាជារូបព្រះបាទជ័យវរ្ម័នទី៧។ រូបទាំងនោះគេបានរកឃើញនៅកន្លែងផ្សេងៗគ្នា គឺនៅក្រោលរមាស( ក្បែរអង្គរធំ) បន្ទាយបាកាន្ត ប្រាសាទភីមាយ( បច្ចុប្បន្ននៅក្នុងទឹកដីប្រទេសថៃឡង់ដ៍)។ មានព្រះកេសមួយទៀតដែលគេសន្និដ្ឋានថាជាព្រះកេសនៃព្រះបាទជ័យវរ្ម័នទី៧ដែរហើយដែលគេយកទៅតម្កល់តាំងនៅសារមន្ទីរ Guimet នៅក្រុងប៉ារីស៍រហូតដល់សព្វថ្ងៃ ប៉ុន្តែដែលគេពុំចាំប្រកពច្បាស់ គ្រាន់តែសង្ស័យថាប្រហែលជាបានមកពីប្រាសាទតាព្រហ្ម (រូបលេខ៦)។ នៅឆ្នាំ១៩២២ គេក៏ធ្លាប់ឃើញរូបដងខ្លួនមនុស្សអង្គុយលើជើងទម្រមួយដែរ(រូបលេខ៧) តែដោយប្រការអ្វីមួយដែលយើងពុំយល់ស្ថានភាពបច្ចុប្បន្ន គឺដងខ្លួនស្ថិតនៅពាយប៉ាយជាមួយគំនរថ្មដ៏ទៃ រីឯ ព្រះកេសវិញទៅនៅបរទេស។ ឥឡូវនេះក្រោយពីការវាស់វែងនៅកន្លែងពីរផ្សេងគ្នានេះទៅ យើងសង្ស័យខ្លាំងណាស់ថា ទាំងអស់នេះជាផ្នែកផ្សេងគ្នានៃរូបតែមួយ។ ក្រុមចុះបញ្ជីយើងបានប្រមូលផ្នែកទាំងប៉ុន្មានដែលបង្ហាញនៅរូបលេខ៨-១០ ( ព្រះកាយ) និងលេខ១១-១២ ( ព្រះភ្នែន និងព្រះបាទ) ទៅរក្សាទុកនៅទីស្នាក់ការអាជ្ញាធរអប្សរាជាបណ្ដោះអាសន្នសិន ។


រូបលេខ៦ (© Musée Guimet)


រូបលេខ៧ (© EFEO)


រូបលេខ៨


រូបលេខ៩


រូបលេខ១០


រូបលេខ១១


រូបលេខ១២


រូបលេខ១៣

ក្រោយពីដើមស្ពង់មួយដើមរលំដួលកាលពីឆ្នាំ២០១២ដូចបាននិយាយនៅខាងលើ។ ដោយសារតែប្រអប់ដៃសំពះមួយនេះធំមានបណ្តោយ ២៩ស.ម ទទឹង ១៧ស.មនិងកម្រាស់ ១៤ស.ម(រូបលេខ២១៣) ទើបយើងគិតថា តើមានដៃទេពណាដែលមានប្រអប់ធំយ៉ាងនេះ? បើគិតទៅព្រះពុទ្ធ និងព្រះលោកេស្វរគឺមិនដែលមានកាយវិការសំពះឡើយ បើទេពផ្សេងៗក៏មិនមានកាយវិការដូចនេះដែរ។ ដូច្នេះយើងក៏គិតថាប្រអប់ដៃនេះប្រហែលអាចជាព្រះហស្តរបស់ព្រះបាទជ័យវរ្ម័នទី៧ ដោយសារអ្នកជំនាញថ្មនៃនាយកដ្ឋានយើងបានវិភាគថា ព្រះភ្នែន ព្រះកាយ និងព្រះហស្តគឺជាថ្មតែមួយ។ ការគិតនេះហាក់ដូចជាសមស្របនឹងគំនិតអ្នកប្រាជ្ញមួយចំនួនកាលពីសម័យមុនៗដែរ ដែលគិតថា កាលរូបនៅពេញលេញ ព្រះហស្តព្រះបាទជ័យវរ្ម័នទី៧មានកាយវិការសំពះ ប៉ុន្តែមានអ្នកប្រាជ្ញផ្សេងទៀតយល់ថាព្រះអង្គមានកាយវិការសមាធិទៅវិញ។ សូមបញ្ជាក់ថា កាលពីមុនមកពុំធ្លាប់ប្រទះឃើញប្រអប់ដៃធំយ៉ាងដូចនេះទេ។

## ១.៣. ព្រះពុទ្ធរូប

កាលដែលគេជួសជុលអាគារដែលនិយមហៅថា“សាលរបាំ” នៅប្រាសាទតាព្រហ្មនេះ គេប្រទះឃើញរូបចម្លាក់ព្រះពុទ្ធរូបពីរកន្លែង៖មួយនៅជ្រុងឦសានជាប់នឹងសាលរបាំ(រូបលេខ២១៤,១៥) និងមួយទៀតនៅខាងជើងសាលរបាំ (រូបលេខ២១៦-១៧)។ ប្រការត្រង់នេះធ្វើឲ្យខ្ញុំនឹកឃើញទៅដល់ព្រះពុទ្ធប្រក់នាគហៅថា “ជ័យពុទ្ធមហានាថ” ជាព្រះដ៏ធំជាងគេនៅប្រាសាទបាយ័ន្តហើយដែលក្រោយមកបន្តិចគេទម្លាក់ចោលក្នុងអណ្តូងប្រាសាទនោះ ដោយសារពេលនោះខ្មែរដូរមកកាន់ព្រហ្មញ្ញសាសនាមួយរយៈវិញ។ ក្នុងចំណោមរូបទាំងពីរដែលកប់ក្នុងដីនៅប្រាសាទតាព្រហ្មនេះអាចជារូបណាដែលនៅជ្រុងឦសានជាទេពសំខាន់ខ្លាំងនៃប្រាសាទតាព្រហ្ម ត្បិតមានទំហំធំ ពោលគឺកម្ពស់២.៣៥ម. គិតទាំងព្រលួញតែពុំគិតព្រះសិរទេដោយសារបាត់ទៅហើយ។


រូបលេខ២១៤


រូបលេខ២១៥


រូបលេខ២១៦


រូបលេខ២១៧

## ១.៤. អលង្ការផ្ទូងសក់

ការប្រទះឃើញដងខ្លួនទាំងមូលនៃព្រះពុទ្ធអង្គដោយពុំឃើញព្រះសិរនោះ ជំរុញឲ្យអ្នកស្រាវជ្រាវធ្វើកំណាយតទៅទៀតទេ តែពុំបានប្រទះព្រះសិរដូចបំណងឡើយ ប៉ុន្តែបានជួបវត្ថុផ្សេងដែរ ពោលគឺអលង្ការធ្វើអំពីមាសសម្រាប់ស៊កផ្ទូងសក់ (រូបលេខ២១៨)[១]។ យើងបានប្រគល់អលង្ការផ្ទូងនេះទៅសារមន្ទីរជាតិក្រុងភ្នំពេញដើម្បីរក្សាទុក។



រូបលេខ២១៨



រូបលេខ២១៩

## ២. ប្រាសាទនាគព័ន្ធ

កាលពីឆ្នាំ២០១០ យើងបានធ្វើកំណាយស្រាវជ្រាវនៅប្រាសាទនាគព័ន្ធ ដោយបានបើករណ្តៅចំនួន៤ នៅជុំវិញតួប៉មស្រះកណ្តាល។ រណ្តៅខាងកើតហៅថារណ្តៅJ ខាងជើងគឺរណ្តៅK ខាងត្បូងគឺរណ្តៅI និងខាងលិចហៅថារណ្តៅH។ រណ្តៅH ជារណ្តៅដែលមានវត្ថុច្រើនជាងគេ។ នៅគ្រប់រណ្តៅ យើងបានប្រទះឃើញនូវវត្ថុផ្សេងៗមួយចំនួនដូចជា ៖ ដុំក្លាតតូចៗ បំណែកថ្មដែលមានជាប់ស្នាមហ្វូសីលសត្វខ្យងសមុទ្រពពួកអាម៉ានីត និងថ្មរាងទ្រវែងរាងតូចៗជាច្រើនដែលយើងសង្ស័យខ្លាំងថានៅជំនាន់នោះគេសម្គាល់ថាជាលិង្គ។ ដូច្នេះយើងប្រើពាក្យជាបណ្តោះអាសន្នថា “លិង្គ” ដើម្បីសំដៅលើថ្មទាំងនេះ។

### ២.១. លិង្គ

ទាំងអស់មានចំនួន២៣ដុំ ដែលមានប្រវែងចាប់ពី៧ទៅដល់២៧ស.ម.។ ក្រៅពីទំហំនិងប្រវែងដែលមិនដូចគ្នា ប្រភេទថ្មដែលយកមកធ្វើលិង្គទាំងនោះក៏ផ្សេងៗគ្នាដែរ។ ជាទូទៅមានភិនភាគប្រហាក់ប្រហែលគ្នា ពោលគឺមានរាងមូលទ្រវែងឯខាងចុងវិញរាងទាលបន្តិចដួនកាលស្តួចជាងនៅផ្នែកកណ្តាល។ យើងអាចបែងចែកលិង្គទាំងនេះជា២ក្រុម។ក្រុមទី១មើលទៅឃើញថាជាថ្មធម្មជាតិដែលគ្មានការកែច្នៃ ឯក្រុមទី២មាន

[១] អ្នកសិក្សាផ្នែកបដិមាសាស្ត្រអាចប្រៀបធៀបអលង្ការនេះទៅរូបលេខ២១៩ ដែលជារូបស្រីស្នំនៅប្រាសាទបន្ទាយក្តី។

លំនាំទូទៅជាធម្មជាតិដែរ តែដែលមនុស្សបានកែច្នៃដោយអន្ទើៗ ក្រុមទី១មាន១៥ដុំ រាងស្រដៀងផ្លែត្រសក់ ហើយកោងបន្តិច មានប្រវែងពី៥,៥ ស.ម. ទៅ ២៧ ស.ម. និងមានកម្រាស់ពី ២,១ ស.ម. ដល់៣,៥ ស.ម.ៗ រូបលេខ២០ជាលិង្គក្នុងពពួកក្រុមទី១ ហើយឃើញទំនងជាថ្មធម្មជាតិដែលមិនមានការកែច្នៃអ្វីទាំងអស់។ បើមើលមករូបលេខ២១វិញ យើងឃើញថាសមាសជាតុថ្មខុសពីមុនបន្តិច ហាក់ដូចជាមានកម្ទេចត្បូងនៅលាយឡំជាមួយសាច់ថ្ម។

ប្រភេទទី២មាន១២ដុំរាងមូលទ្រវែងដែរខ្លះគេលាក់ចុងម្ខាងឲ្យមានទំហំតូចទំនងជាដើម្បីបញ្ចូលទៅក្នុងអ្វីមួយ (រូបលេខ២២) ខ្លះទៀតមានចោះជារន្ធពីម្ខាងទៅម្ខាងដែលយើងមិនយល់មូលហេតុ (រូបលេខ២៣) លិង្គនៅរូបលេខ២៤ជាថ្មដែលហាក់ដូចជាមានជាប់ជាតិច្រេះឬស្នឹមនៃលោហៈអ្វីមួយ រីឯរូបលេខ២៥វិញ មានសាច់ថ្មដែលហាក់ដូចជាមានជាតិកំបោរច្រើនតែរឹងមាំមិនផុយរលាយក្នុងទឹកឡើយៗវត្ថុពីរខាងក្រោយនេះទំនងជាគេរៀបចំឲ្យដូចលិង្គធម្មជាតិ។


រូបលេខ២០


រូបលេខ២១


រូបលេខ២២



រូបលេខ២៣


រូបលេខ២៤


រូបលេខ២៥

## ២.២. អាម៉ូនីត

រូបលេខ២៦ បង្ហាញពីបំណែកថ្មមួយមានជាប់ស្នាមហ្វូសីលសត្វខ្យងសមុទ្រពពួកអាម៉ូនីត (Ammonite)។ ឯរូបលេខ២៧ជាអាម៉ូនីតមួយទៀតដែលមិនទាន់យកចេញពីស្រទាប់ដីហើយដែលឃើញមានលិង្គមួយនៅជិតនោះ។



រូបលេខ២៦



រូបលេខ២៧

## ៣. ភូមិត្រពាំងសេះ

កាលថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៣ នៅមុខអង្គរវត្ត ខាងត្បូងប្រាសាទបាយក្អែក (ភូមិត្រពាំងសេះ) ក្នុងការងាររឈូសធ្វើផ្លូវមួយ គេប្រទះឃើញពាងឬផើងបុរាណមួយធំល្មម កំពស់២៨ ស.ម. ទទឹង ៣៦ ស.ម. (រូបលេខ២៨)។ ក្នុងពាងនេះមានជន្ទាប់និងខ្ចចប្រាំដែលលិចចេញពីកំណាកដី។ យើងពុំទាន់យកវត្ថុទាំងអស់ចេញមកក្រៅនៅឡើយ (រូបលេខ២៩-៣០) បើកាយកំណាកដីចេញអស់ អាចឃើញមានផ្ទុកវត្ថុផ្សេងទៀតនៅខាងក្នុង។ ជន្ទាប់ទាំងនោះជាប្រភេទកុលាលភាជន៍ចិនសម័យសុង។



រូបលេខ២៨



រូបលេខ២៩



រូបលេខ៣០

## ៤. ប្រាសាទត្រពាំងល្ពៅ

ពីឆ្នាំ២០០៤ដល់២០១៤មានកំណាយស្រាវជ្រាវនិងសង្គ្រោះដឹកនាំដោយវិទ្យាស្ថានឈ្មោះInstitut National de Recherches Archéologiques Préventives (INRAP) ក្នុងសហការជាមួយអាជ្ញាធរអប្សរា ដោយសារមានការសាងសង់និងពង្រីកវាលយន្តហោះអន្តរជាតិសៀមរាប-អង្គរ។ ក្នុងចំណោមទីតាំងកំណាយទាំងប៉ុន្មានមានទួលតូចមួយហៅថាទួលEស្ថិតនៅក្រោយប្រាសាទត្រពាំងល្ពៅ( ស.វទី១០) ដែលគេបានដឹកប្រទះឃើញវត្ថុជាដែកពេញលេញមួយ ប្រវែង១៩ស.ម. មានផ្ទៃពីរអាចបត់បានដោយសារមានកន្ទាស់។ បើមើលពីចំហៀង ដងកាន់មានរាងកោង ចំណែកចុងនៅខាងមុខងឡើងបន្តិច ដែលអាចឲ្យយើងសន្និដ្ឋានបានថាជាប្រណាកធាកស្លា (រូបលេខ៣១)។ ប្រហែលជាលើកទីមួយហើយដែលគេប្រទះឃើញឧបករណ៍នេះនៅក្នុងកំណាយ។ នៅជិតប្រណាកនេះគេឃើញខ្ចួចមួយធ្វើអំពីដីដុតរឹង(រូបលេខ៣២) ស្ទើរតែពេញរូបរាង មានកំបោរនៅក្នុង ជាការបញ្ជាក់ឲ្យកាន់តែច្បាស់ថាវត្ថុទាំងពីរសេសសល់ពីសំណុំគ្រឿងហូបស្លាទាំងមូល ដែលហៅថាហឹបស្លា។



រូបលេខ៣១ (©INRAP)



រូបលេខ៣២ (©INRAP)

## ៥. ប្រាសាទកាបិលប្ញូរ

កបិលបូរជាឈ្មោះភូមិមួយនៅក្បែរប្រាសាទនេះកាលពីសម័យបុរាណ បើយោងតាមសិលាចារឹកចារលើមេទ្វារ( ស.វ.ទី១០)។ អ្នកស្រុកសព្វថ្ងៃហៅប្រាសាទនេះថា“ប្រាសាទតុប” ដែលស្ថិតនៅទិសឦសានកសិន្ធុអង្គរវត្តចំងាយប្រមាណ៣០០ម៉ែត្រ។ប្រាសាទនេះមានប្រាង្គចំនួនបីដោយតួប៉មពីរបែរមុខទៅកើតធ្វើពីឥដ្ឋរាងបួនជ្រុងស្មើ ហើយមានសំណង់មួយទៀតរាងចតុកោណកែង បែរទៅខាងលិច ធ្វើពីថ្មបាយក្រៀមដែលអាចជាបណ្ណាល័យ។

នៅឆ្នាំ២០១៧ យើងបានធ្វើកំណាយស្រាវជ្រាវនៅប្រាសាទនេះ ក្នុងគោលបំណងបញ្ចៀសទឹកចេញពីប្រាសាទនៅពេលដែលមានភ្លៀងធ្លាក់។ យើងបានជ្រើសរើសផ្នែកខាងជើងប៉មទាំងបីនៃប្រាសាទដើម្បីធ្វើកំណាយ ហើយក៏បានជួបប្រទះនឹងជើងទម្រពីរ ធ្វើពីថ្មភក់ ដែលមានចង្អូរចំពួយបែរទៅខាងជើងជាធម្មតា។

ជើងទម្រទាំងពីរស្ថិតនៅក្បែរតួប៉មខាងជើង (រូបលេខ៣៣-៣៥)។ ទាំងពីរនេះមានសណ្ឋានទ្រង់ទ្រាយនឹងទំហំប្រហាក់ប្រហែលគ្នា ដាក់តម្រៀបលើកំណល់ថ្មបាយក្រៀមតែមួយ។ ជើងទម្រមួយនៅជាប់នឹងជញ្ជាំងរណ្ដៅកំណាយ ឯមួយទៀតនៅចំកណ្ដាលរណ្ដៅតែម្ដង ខ្លួនមានបណ្ដោយប្រវែង ៦៥ ស.ម. (៩០ ស.ម. បើទាំងបើគិតទាំងចង្អូរបង្ហូរទឹកផ្នែកខាងលើ) ទទឹង៦០ ស.ម. និងកម្ពស់៤៥ ស.ម.។ នៅផ្ទៃខាងលើជើងទម្រនេះមានចោះជារន្ធសម្រាប់ស៊កដាក់តម្កល់លិង្គឬបដិមាអ្វីមួយ។រន្ធនោះមានរាងចតុកោណស្មើរជ្រុងស្មើគ្នាហើយរីកជាក្អេងធំទៅខាងក្រោម។



រូបលេខ៣៣



រូបលេខ៣៤



រូបលេខ៣៥

នៅខាងក្រោមជើងទម្រនេះមានរណ្ដៅដែលផ្នែកក្រោមជាខ្សាច់ ហើយដែលលើនោះមានស្រទាប់ថ្មបាយក្រៀមប្រើជាកំណាល់។ ស្រទាប់រណ្ដៅនេះ រៀបចំឡើងដើម្បីបញ្ចុះវត្ថុផ្សេងៗស្របទៅតាមក្បួនជំនឿសម័យនោះ (រូបលេខ៣៦)។




រូបលេខ៣៦

នៅខាងក្រោមជើងទម្រនេះ គេបានជីកជារណ្ដៅតូចល្មមមួយដាក់វត្ថុផ្សេងៗដែលគេបានបញ្ចុះតាមលំដាប់លំដោយតាមជំនឿ(រូបលេខ៣៨,៣៩,៤០,៤១)។វត្ថុដែលបញ្ចុះមានដូចជា៖ បំពង់លោហៈ( ស្ពាន់? ) មានរាងមូលទ្រវែង ដោយមានបណ្ដោយប្រវែង៣៣ ស.ម និងទំហំអង្កត់ ផ្ចិតពី២, ៥០ ស.ម ទៅ៣, ០០ ស.ម និងកម្រាស់ប្រហែល២ ម.ម។ បំពង់លោហៈនេះត្រូវបានរៀបដាក់បញ្ឈរត្រង់ ចំកណ្ដាលក្រោមជើងទម្រ ( ចាប់ពីបាតជើងទម្រចុះមកក្រោម) រហូតមកទល់នឹងផ្ទៃនៃបន្ទះ ( ថាស) លោហៈ។ បំពង់លោហៈនេះ មានសភាពបាក់ជា៣កំណាត់ និងពុកផុយខ្លាំង។ បំពង់របៀបនេះ ព្រមទាំងសន្ទឹកមាស មានក្បាច់និងក្វាតពីរដុំក៏ធ្លាប់បានរកឃើញដោយលោកHenri Marchal កាលពីឆ្នាំ១៩២៤ នៅតួប៉មថ្មបាយក្រៀមខាងត្បូងនៃប្រាសាទកបិលបូរនេះតាមរបាយការណ៍របស់គាត់។ តែរបស់នេះសព្វថ្ងៃយើងមិនបានរកឃើញនៅសារមន្ទីរជាតិ

វត្ថុបញ្ចុះដែលភ្ជាប់ទៅជើងទម្រផ្ទាល់គឺបំពង់លោហៈ( ស្ពាន់? )មួយមានរាងមូល,បណ្ដោយ៣៣ស.ម., អង្កត់ផ្ចិតពី២,៥០ស.ម.ទៅ៣ស.ម.,កម្រាស់រវាង២ម.ម.(រូបលេខ៣៧)។ បំពង់នេះគេរៀបដាក់បញ្ឈរត្រង់ចុងម្ខាងទៅទល់ចំកណ្ដាលទម្រឯចុងម្ខាងទៀតចុះមកទល់នឹងបន្ទះថាសមួយមូលស្ដើងធ្វើពីលោហៈដូចគ្នាដែរ តែហាក់ដូចជាគ្មានឃើញស្នាមផ្សារឲ្យជាប់គ្នាឡើយ (រូបលេខ៣៨)។ ដោយសារពុកផុយខ្លាំង ពេលយកចេញពីដីមក បំពង់នេះបាក់ជា៣កំណាត់។

ឯបន្ទះលោហៈវិញមានអង្កត់ផ្ចិត៤៥ស.ម.,កម្រាស់មិនស្មើគ្នាទេគឺប្រមាណពី១ទៅ២ម.ម.(រូបលេខ២៣៩)។ ដោយសារតែបន្ទះនេះស្តើងពេកនិងពុកផុយខ្លាំងផង ទើបពេលធ្វើកំណាយទៅក៏បែកជាច្រើនបំណែកតូចៗរហូតជាង៥០បំណែក (រូបលេខ២៤០) ។



រូបលេខ២៣៧



រូបលេខ២៣៨



រូបលេខ២៣៩



រូបលេខ២៤០

នៅក្រោមថាស ចំចំណុចកណ្តាល មានដុំលោហៈតូចមួយដុំ (សំណ?) រាងមូលបន្តិច ដែលមានអង្កត់ផ្ចិតប្រមាណជា២,៥ស.ម. (រូបលេខ២៤១)។ នៅជុំវិញនោះ មានដុំក្វាតចំនួន៤ដុំដែលមានទំហំចន្លោះពី០,០៥ស.ម.ទៅ០,១០ស.ម. (រូបលេខ២៤២)។ ឯក្នុងស្រទាប់ខ្សាច់ទាំងមូលនេះ គេឃើញមានសន្លឹកមាសស្តើងៗជាច្រើនសន្លឹកនៅលាយឡំគ្រប់កន្លែងក្នុងដីខ្សាច់។ សន្លឹកខ្លះអាចនៅក្នុងសភាពដើម តែមានច្រើនទៅទៀតដែលដាច់ដោចនៅពេលក្រោយ (រូបលេខ២៤៣)។

សូមបញ្ជាក់ថាវត្ថុបញ្ចុះប្រភេទនេះ លោក Henri Marchal ធ្លាប់ប្រទះឃើញម្តងហើយនៅក្នុងកំណាយមួយដែលគាត់ធ្វើនៅឆ្នាំ១៩២៤នៅតួប៉មថ្មបាយក្រៀមខាងត្បូងនៃប្រាសាទកបិលបូរដែលនេះៗវត្ថុទាំងនេះសព្វថ្ងៃមិនដឹងនៅឯណាឡើយ។ បើនៅប្រាសាទបាយក្អែកវិញ កាលពីឆ្នាំ១៩៦៧ លោក Bernard-Philippe Groslier បានរកឃើញបំពង់របៀបនេះពីរ។ មួយមានរាងវែងជាប់នឹងបន្ទះបួនជ្រុងសំប៉ែត (រូបលេខ២៤៤) និង

មួយទៀតរាងខ្ចីតែពុំឃើញភ្ជាប់ជាមួយអ្វីឡើយ (រូបលេខ២៤៥)។ វត្ថុទាំងនេះ គេរក្សាទុកនៅសារមន្ទីរជាតិភ្នំពេញ។

ផ្នែកក្នុងដីក្រោមជើងទម្រនៅប្រាសាទកបិលបូរនេះគួរជាទីពិចារណា។ យើងអាចស្មានជាសម្មតិកម្មថាពេលគេស្រោចស្រប់លិង្គឬបដិមាដែលតម្កល់លើនោះទៅទឹកឬវត្ថុរាវអ្វីមួយដែលប្រើសម្រាប់កិច្ចនោះហូរចុះទៅក្រោមដោយឆ្លងកាត់តាមបំពង់លោហៈរហូតដល់បន្ទះរាងមូលហើយទើបសាយភាយប៉ះដល់ស្រទាប់ខ្សាច់ដែលក្នុងនោះមានវត្ថុបញ្ចុះផ្សេងៗដែលបានពោលមកហើយ។




រូបលេខ២៤១



រូបលេខ២៤២



រូបលេខ២៤៣




រូបលេខ២៤៤ (© Brice Vincent)




រូបលេខ២៤៥ (© Brice incent)

## ៦. ទូក

នៅខែមីនា ឆ្នាំ២០០៩ អ្នកស្រុកនៅភូមិក្រសាំងរលើង ក្នុងក្រុងសៀមរាប បានប្រទះឃើញទូកមួយកប់ក្នុងដីក្នុងជម្រៅប្រមាណ១,៣០ម.ពេលដែលជីកដីធ្វើស្រះចិញ្ចឹមត្រី។ ទូកដែលមានប្រវែងដល់ទៅ១៥ម.កើត

ឡើងពីការលុងដើមឈើទាំងមូលមួយនេះ ទំនងជាមានចំណាស់ច្រើនគួរសម(រូបលេខ២៨៦)។កន្ទៃងដែលរកឃើញនេះនៅម៉ុំទំនប់បុរាណមួយ ដែលសព្វថ្ងៃក៏នៅអាចមើលយល់ថាជាទំនប់ដែរថ្វីត្បិតតែខូចខាតអស់ច្រើន។ តាមពិតនៅបុរាណកាលមានព្រែកជីកមួយចេញពីខាងត្បូងប្រាសាទអង្គរវត្តចាក់ទៅទន្លេសាប ដោយកាត់តាមក្បែរជល់ភ្នំក្រោម។ អ្នកស្រាវជ្រាវដឹងថា ផុតពីក្លោងទ្វារក្រៅខាងលិចនៃប្រាសាទវត្តអធ្វាភ្វាមទៅមានកំពង់ចំណតមួយនៅមាត់ព្រែកនោះតែម្តង។ នេះជាការដែលធ្វើឲ្យយើងសង្ស័យថា ទូកនេះមានចំណាស់ ដ្បិតគេប្រទះឃើញនៅម៉ុំព្រែកនោះតែម្តង។ លុះបញ្ជូនបំណែកឈើតូចមួយទៅពិនិត្យនៅមន្ទីរពិសោធន៍មួយនៅប្រទេសបារាំង ក៏ឃើញថាជាឈើគគីរដែលមានចំណាស់ច្រើនរយឆ្នាំហើយដែរ គឺនៅចន្លោះស.វ.ទី១៤ នឹង ស.វ.ទី១៦។

បើទុកទូកនោះចោលនៅកណ្តាលវាលដូច្នេះ ឃើញថាពុំយូរពុំឆាប់មុខជាខូចខាតអស់។ យើងក៏សម្រេចចិត្តយកមកពន្ធិចរក្សាទុកនៅក្នុងកសិន្ធុអង្គរវត្តប៉ែកខាងលិច នៅមុខគុកតារាជ (រូបលេខ២៨៧)។

ប្រាំមួយឆ្នាំតពីនោះមកទៀត ក្នុងឆ្នាំ២០១៥ អ្នកស្រុកនៅភូមិបំពេញរាជ ឃុំលាងដៃ ក៏បានប្រទះទូកមួយទៀតដោយចៃដន្យដែរ (រូបលេខ២៨៨) ដែលមានរូបរាងនិងប្រវែងប្រហាក់ប្រហែលនឹងទូកខាងលើដែរ។ តែដោយសារនៅថ្មីជាងយើងគិតថាចំណាស់ក៏តិចជាងដែរ។ដើម្បីរក្សាជាបណ្តោះអាសន្នយើងក៏យកមកទុកក្នុងកសិន្ធុអង្គរវត្តដូចមុនដែរ។



រូបលេខ២៨៨



រូបលេខ២៨៧



រូបលេខ២៨៦

# ឯកសារយោង


*នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ, កម្រោងរបាយការណ៍, អាជ្ញាធរអប្សរា ២០១៣។*

*ព្រាប ចាន់ម៉ារ និង ជា សុជាតិ, ព្រះបរមរូបព្រះបាទជ័យវរ្ម័នទី៧, ភ្នំពេញ, ២០១៦។*

*កឹង តារា, រូបចម្លាក់រកឃើញថ្មីនៅប្រាសាទតាព្រហ្ម, បណ្ដាញពត៌មានវប្បធម៌ខ្មែរ, ជំពូក៤, ៤. លេខរៀង៦១* http://www.yosothor.org/publications/khmer-renaissance/chapter-four/roub-jomlak-rok-khernh-thmey-nov-prasat-taprohm.html

*លឹម ស្រ៊ូ, ប្រាសាទនាគព័ន្ធ និងជំនឿក្នុងការព្យាបាលជម្ងឺ, កម្រងអត្ថបទក្នុងបណ្ដាញពត៌មានវប្បធម៌ខ្មែរ, លេខ៥, ជំពូក២ ជំនឿ ទំនៀមទម្លាប់។*

*អាំង ជូលាន, អេរិក ប្រេណូរិត្ស, អាស្ទីថមសុន, អង្គរ អតីត-បច្ចុប្បន្ន-អនាគត, អាជ្ញាធរអប្សរា ១៩៩៨។*

*អន សុភាព, ទូកចាស់ប្រទះឃើញនៅតំបន់អង្គរ, បណ្ដាញពត៌មានវប្បធម៌ខ្មែរ, ជំពូក៤,លេខរៀង២៨* http://www.yosothor.org/publications/khmer-renaissance/chapter-four/tuk-jas-proteas-khernh-nov-domban-angkor.html)

BAPTISTE Pierre et ZEPHIR Tirierry, 2008, *L'art khmer dans les collections du Musée Guimet*, RMN Réunion des Musées Nationaux.

Christophe POTTIER, 2015, Le Roi dans le temple: le cas de Jayavarman VII, de Phimai à Angkor, Bulletin d'études indiennes, no. 33, p. 446-447.

Louis Finot, 1925, Inscriptions d'Angkor, *BEFEO,* 25/3-4, p. 297-407.

Le Conseil International des Musées (ICOM), 1993, *Cent Objects Disparus / One Hundred Missing Objects*.

International Council of Museums, 1993, *One hundred missing objects : looting in Angkor*, ICOM : Ecole française d'Extrême-Orient, Paris.

MARCHAL, Henri, 1923, *Journal de fouilles*, vol. 4, juillet, P.194-195.

POTTIER, Christophe, 1997, Tableau des dépôts de fondation mis au jour par la conservation d'Angkor, *BEFEO*, 84, Paris, p.400-401.

Pierre, Bâty, 2011, Aéroport de Siem Reap Tertre E à Prasat Trapeang Ropou, *VI. Analyse des données et synthèse de l'occupation du site,* Cambodge, Rapport, p.106-112.

Phoeung Dara, 2010, *Neak Poan temple and Archaeological Research*, Cultural Asia-Pacific Centre for UNESCO (ACCU) office, Nara.

Rapport de la Conservaion d'Angkor, juillet 1924.

# កម្រងរូបសំខាន់ៗផ្សេងទៀត



ឈ្មោះ÷លិង្គព្រះឥសូរ

លេខបញ្ជី÷ AA.DCMA.2008.4

ប្រភព÷ ភូមិកន្ទ្រក

សម័យកាល÷ ដើមស.វទី

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷១៣៣×៤០×៤០



ឈ្មោះ÷ដងខ្លួនហេវជ្រ

លេខបញ្ជី÷ AA.DCMA2009.5

ប្រភព÷ខ្លោងទ្វារខ្មោច

សម័យកាល÷ដើមស.វទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷១៥០×៦០×១០៥



ឈ្មោះ÷ ដងខ្លួនទេពរូបប្រុស

លេខបញ្ជី÷ AA.DCMA2009.47

ប្រភព÷ប្រា.បឹងមាលា

សម័យកាល÷ដើមស.វទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷៧៥×១៥៥×៤៥



ឈ្មោះ÷សន្ទឹករកា

លេខបញ្ជី÷AA.DCMA.2008.11

ប្រភព÷ព្រលានយន្តហោះ

សម័យកាល÷ចុងស.វទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷២៦×៣៥×១៣



ឈ្មោះ÷ អប្សរ ឬស្រីស្នំ

លេខបញ្ជី÷ AA.DCMA2009.44

ប្រភព÷ប្រា.តាព្រហ្ម

សម័យកាល÷ចុងស.វទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷២១×១៧×១២



ឈ្មោះ÷ ភ្នែនព្រះពុទ្ធ ?

លេខបញ្ជី÷AA.DCMA.2008.6

ប្រភព÷ប្រាសាទព្រះខ័ន

សម័យកាល÷ចុងស.វទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷៤៧×៣៧×១៨



| | |
|---|---|
| ឈ្មោះ៖ព្រះសិរប្រក់នាគ | |
| លេខបញ្ជី÷ AA.DCMA2009.50 | |
| ប្រភព÷ប្រាសាទបាខែង | |
| សម័យកាល÷សម័យថ្មី ? | |
| វត្ថុ÷ថ្មភក់ | |
| ខ្នាត(សម)÷៣០×១៥×៦២ | |



| | |
|---|---|
| ឈ្មោះ÷កំពូលហោជាង | |
| លេខបញ្ជី÷ AA.DCMA2009.49 | |
| ប្រភព÷ប្រាសាទលលៃ | |
| សម័យកាល÷ស.វទី៨ ? | |
| វត្ថុ÷ថ្មភក់ | |
| ខ្នាត(សម)÷៦៥×៧៥×២៥ | |



| | |
|---|---|
| ឈ្មោះ÷ព្រះហស្ត | |
| លេខបញ្ជី÷ AA.DCMA2009.54 | |
| ប្រភព÷? | |
| សម័យកាល÷ស.វទី៨ ? | |
| វត្ថុ÷ថ្មភក់ក្រហម | |
| ខ្នាត(សម)÷១៨×១២×? | |



| | |
|---|---|
| ឈ្មោះ÷ភ្នែនព្រះពុទ្ធ ? | |
| លេខបញ្ជី÷ AA.DCMA2009.50 | |
| ប្រភព÷ប្រាសាទព្រះខ័ន | |
| សម័យកាល÷ចុងស.វទី១២ | |
| វត្ថុ÷ថ្មភក់ | |
| ខ្នាត(សម)÷៤៤×៤៣×២៧ | |



| | |
|---|---|
| ឈ្មោះ÷ព្រះពុទ្ធប្រក់នាគ | |
| លេខបញ្ជី÷ AA.DCMA2009.54 | |
| ប្រភព÷ | |
| សម័យកាល÷ចុងស.វទី១២ | |
| វត្ថុ÷ថ្មភក់ | |
| ខ្នាត(សម)÷៤០×២០×១៧ | |



| | |
|---|---|
| ឈ្មោះ÷បំណែកផ្តែរ | |
| លេខបញ្ជី÷ AA.DCMA2009.63 | |
| ប្រភព÷ប្រាសាទបន្ទាយស្រី | |
| សម័យកាល÷ស.វទី១០ | |
| វត្ថុ÷ថ្មភក់ | |
| ខ្នាត(សម)÷២៣×២៨×១៨ | |

# បុរាណវត្ថុរកឃើញថ្មីៗនៅអង្គរ



ឈ្មោះ÷កញ្ចាំង

លេខបញ្ជី÷ AA.DCMA2009.67

ប្រភព÷ប្រាសាទបន្ទាយស្រី

សម័យកាល÷ ស.វ.ទី១០

វត្ថុ÷ថ្មភក់ក្រហម

ខ្នាត(សម)÷២៨×៤៧×១៩



ឈ្មោះ÷ចុងហោរជាង

លេខបញ្ជី÷ AA.DCMA2009.68

ប្រភព÷ប្រាសាទបន្ទាយស្រី

សម័យកាល÷ ស.វ.ទី១០

វត្ថុ÷ថ្មភក់ក្រហម

ខ្នាត(សម)÷២៤×៥៨×១៤



ឈ្មោះ÷ព្រះសិរលោកេស្វរ

លេខបញ្ជី÷ AA.DCMA2009.75

ប្រភព÷?

សម័យកាល÷ ចុងស.វទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷១៩×៣៣×១៥



ឈ្មោះ÷នព្វគ្រោះ

លេខបញ្ជី÷ AA.DCMA2010.112

ប្រភព÷វត្តប្រាសាទបាគង

សម័យកាល÷ស.វទី៨

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷៤០×២៤×១៤



ឈ្មោះ÷ព្រះកេសលោកេស្វរ

លេខបញ្ជី÷ AA.DCMA2010.114

ប្រភព÷ប្រាសាទតាព្រហ្ម

សម័យកាល÷ចុងស.វទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷១៦×២១×១៥



ឈ្មោះ÷ព្រះពុទ្ធប្រក់នាគ

លេខបញ្ជី÷ AA.DCMA2010.116

ប្រភព÷ ភូមិអូរទទឹង

សម័យកាល÷ចុងស.វទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷១៤×១៧×៩



ឈ្មោះ÷ចែងទ្វារបាល

លេខបញ្ជី÷ AA.DCMA2011.127

ប្រភព÷ឃ្លាំងនគរបាលបេតិកភណ្ឌ

សម័យកាល÷ចុងស.វទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷១៦×២៨×១០



ឈ្មោះ÷ក្បាលយក្ស

លេខបញ្ជី÷ AA.DCMA2011.128

ប្រភព÷ខ្លោងទ្វារជ័យ

សម័យកាល÷ចុងស.វទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷៥០×៤១×៨៦



ឈ្មោះ÷ផ្ដែរ

លេខបញ្ជី÷ AA.DCMA2009.72

ប្រភព÷ប្រាសាទព្រះគោ

សម័យកាល÷ចុងស.វ.ទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷២២៥×៧៧×២៥



ឈ្មោះ÷ថ្មគោល

លេខបញ្ជី÷ AA.DCMA2009.79

ប្រភព÷ទួលគោគភ្លៅ

សម័យកាល÷ចុងស.វ.ទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷១២៦×៤៦×២៩



ឈ្មោះ÷ក្បាលយក្ស

លេខបញ្ជី÷ AA.DCMA2011.129

ប្រភព÷នគរបាលបេតិកភណ្ឌ

សម័យកាល÷ចុងស.វ.ទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷៣៨×៥៧



ឈ្មោះ÷កំប្រុក

លេខបញ្ជី÷ AA.DCMA2011.130

ប្រភព÷នគរបាលបេតិកភណ្ឌ

សម័យកាល÷ចុងស.វ.ទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷១៥×៩



ឈ្មោះ÷ព្រះសិរព្រះពុទ្ធប្រក់នាគ

លេខបញ្ជី÷ AA.DCMA2012.146

ប្រភព÷ប្រាសាទតាព្រហ្ម

សម័យកាល÷ចុងស.វ.ទី១២?

វត្ថុ÷ថ្មភក់

ខ្នាត÷១៦×១៥



ឈ្មោះ÷ព្រះពុទ្ធប្រក់នាគ

លេខបញ្ជី÷ AA.DCMA2012.145

ប្រភព÷ប្រាសាទតាព្រហ្ម

សម័យកាល÷ចុងស.វ.ទី១២?

វត្ថុ÷ថ្មភក់

ខ្នាត÷៥០×២៨



ឈ្មោះ÷ដងខ្លួនទេពរូបស្រី

លេខបញ្ជី÷ AA.DCMA2012.159

ប្រភព÷ប្រាសាទតាព្រហ្ម

សម័យកាល÷ចុងស.វ.ទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷២៩×២៨×១៣



ឈ្មោះ÷ព្រះហស្តដៃខាងឆ្វេង

លេខបញ្ជី÷ AA.DCMA2012.148

ប្រភព÷ប្រាសាទតាព្រហ្ម

សម័យកាល÷ចុងស.វ.ទី១២?

វត្ថុ÷ថ្មភក់

ខ្នាត(សម)÷២១×១៩



| |
|---|
| ឈ្មោះ÷ចម្លាក់រូបទេពដៃ៦? |
| លេខបញ្ជី÷ AA.DCMA2012.166 |
| ប្រភព÷ប្រាសាទតាព្រហ្ម |
| សម័យកាល÷ចុងស.វ.ទី១២? |
| វត្ថុ÷ថ្មភក់ |
| ខ្នាត(សម)÷៣២×២២×៥ |



| |
|---|
| ឈ្មោះ÷ជើងទម្រ |
| លេខបញ្ជី÷ AA.DCMA2012.161 |
| ប្រភព÷ប្រាសាទតាព្រហ្ម |
| សម័យកាល÷ចុងស.វ.ទី១២? |
| វត្ថុ÷ថ្មភក់ |
| ខ្នាត(សម)÷៣៩×២០,៥× |



| |
|---|
| ឈ្មោះ÷បំណែកក្បាលនាគ |
| លេខបញ្ជី÷ AA.DCMA2013.195 |
| ប្រភព÷ភូមិលាងដៃ |
| សម័យកាល÷ចុងស.វ.ទី១២? |
| វត្ថុ÷ថ្មភក់ |
| ខ្នាត(សម)÷៤៤×៣៣×២៧ |



| |
|---|
| ឈ្មោះ÷ព្រះក្អែនលោកេស្វរ ? |
| លេខបញ្ជី÷ AA.DCMA2012.181 |
| ប្រភព÷ប្រាសាទតាព្រហ្ម |
| សម័យកាល÷ចុងស.វ.ទី១២? |
| វត្ថុ÷ថ្មភក់ |
| ខ្នាត(សម)÷៣៦×៣៣×២០ |



| |
|---|
| ឈ្មោះ÷ព្រះសិរលោកេស្វរ |
| លេខបញ្ជី÷ AA.DCMA2013.198 |
| ប្រភព÷ប្រាសាទតានៃ |
| សម័យកាល÷ចុងស.វ.ទី១២? |
| វត្ថុ÷ថ្មភក់ |
| ខ្នាត(សម)÷៦×១១×៩ |



| |
|---|
| ឈ្មោះ÷ទ្វារបាល |
| លេខបញ្ជី÷ AA.DCMA2013.196 |
| ប្រភព÷ភូមិលាងដៃ |
| សម័យកាល÷ចុងស.វ.ទី១២? |
| វត្ថុ÷ថ្មភក់ |
| ខ្នាត(សម)÷៣១×១០០×១៩ |



| |
|---|
| ឈ្មោះ÷កងដៃ |
| លេខបញ្ជី÷ AA.DCMA2014.565 |
| ប្រភព÷ CP526 |
| សម័យកាល÷ចុងស.វ.ទី១២? |
| វត្ថុ÷លោហៈ |
| ខ្នាត(សម)÷៥,៥×០,៣×៣ |



| |
|---|
| ឈ្មោះ÷ដងខ្លួនព្រះពុទ្ធ? |
| លេខបញ្ជី÷ AA.DCMA2013.199 |
| ប្រភព÷ភូមិលាងដៃ |
| សម័យកាល÷ចុងស.វ.ទី១២? |
| វត្ថុ÷ថ្មភក់ |
| ខ្នាត(សម)÷៤៦×៣៨×២៦ |



| |
|---|
| ឈ្មោះ÷ចិញ្ចៀន |
| លេខបញ្ជី÷ AA.DCMA2014.567 |
| ប្រភព÷ប្រាសាទនាគព័ន្ធ |
| សម័យកាល÷ ? |
| វត្ថុ÷ លោហៈ |
| ខ្នាត(សម)÷៥,៥×០,៣×៣ |



| |
|---|
| ឈ្មោះ÷កំណាត់សំពត |
| លេខបញ្ជី÷ AA.DCMA2012.168 |
| ប្រភព÷ប្រាសាទតាព្រហ្ម |
| សម័យកាល÷ចុងស.វ.ទី១២? |
| វត្ថុ÷ថ្មភក់ |
| ខ្នាត(សម)÷៣០×៣៦×១៥ |



| |
|---|
| ឈ្មោះ÷ព្រះសិរបដិមា |
| លេខបញ្ជី÷ AA.DCMA2014.615 |
| ប្រភព÷ ប្រាសាទនាគព័ន្ធ |
| សម័យកាល÷ចុងស.វ.ទី១២? |
| វត្ថុ÷ថ្មភក់ |
| ខ្នាត(សម)÷១៧×១៥×៨,៥ |



| |
|---|
| ឈ្មោះ÷កាំបិត? |
| លេខបញ្ជី÷ AA.DCMA2014.618 |
| ប្រភព÷ប្រាសាទគោកប៉ាទ្រី |
| សម័យកាល÷ចុងស.វ.ទី១៧? |
| វត្ថុ÷ដែក |
| ខ្នាត(សម)÷២៣×២ |



| | 
|---|
| ឈ្មោះ÷សន្ទឹកមាស |
| លេខបញ្ជី÷ AA.DCMA2014.620 |
| ប្រភព÷ ប្រាសាទគោគប៉ាទ្រី |
| សម័យកាល÷ចុងស.វ.ទី១៧? |
| វត្ថុ÷មាស |
| ខ្នាត(សម)÷២,២×២×០,១ |



| |
|---|
| ឈ្មោះ÷អកកំបោរ |
| លេខបញ្ជី÷ AA.DCMA2014.619 |
| ប្រភព÷ ប្រាសាទគោគប៉ាទ្រី |
| សម័យកាល÷ចុងស.វ.ទី១៧? |
| វត្ថុ÷ |
| ខ្នាត(សម)÷ ៨,៣×២,៤ |



| |
|---|
| ឈ្មោះ÷ដងខ្លួនមនុស្សតឿ |
| លេខបញ្ជី÷ AA.DCMA2014.623 |
| ប្រភព÷ ប្រាសាទនាគព័ន្ធ |
| សម័យកាល÷ចុងស.វ.ទី១២? |
| វត្ថុ÷ថ្មភក់ |
| ខ្នាត(សម)÷៥៨×៣៤×៣៦ |



| |
|---|
| ឈ្មោះ÷ព្រះសិរព្រះពុទ្ធ |
| លេខបញ្ជី÷ AA.DCMA2014.621 |
| ប្រភព÷ ប្រាសាទគោគប៉ាទ្រី |
| សម័យកាល÷ចុងស.វ.ទី១៧? |
| វត្ថុ÷ ថ្មភក់ |
| ខ្នាត(សម)÷១០×៥×៣,៩ |



| |
|---|
| ឈ្មោះ÷ព្រះសិរព្រះឥសូរ |
| លេខបញ្ជី÷ AA.DCMA2014.633 |
| ប្រភព÷ប្រាសាទតាកែវ |
| សម័យកាល÷ចុងស.វ.ទី៩? |
| វត្ថុ÷ថ្មភក់ |
| ខ្នាត÷៣៨×២១×២០ |

# ANGKOR AS A CULTURAL CONTINUUM

Sachchidanand Sahai

ABSTRACT

The paper questions the validity of the watertight tripartite division of Angkor civilization, imposed by the nineteenth-twentieth century writings. The truth is that Angkor continues even in the 21st century by embedded time-honored practices followed by the present-day Khmer.

Key words: tripartite division of Angkor Civilization.

The history of Angkor has been divided into a number of political segments such as Funan, Pre-Angkor and Angkor. These segments may mark dynastic changes, political rupture; but hardly there is any cultural rupture. The story of Angkor is a story of continued cultural refinement. The thread of continuity was so strong that political upheavals were absorbed and changes were fine-tuned. Pre-Angkor, Angkor and Post-Angkor represent a classification for convenience sake. In Angkor exists a number of important pre-Angkor monuments and inscriptions. The situation is of pre-Angkor in Angkor. The tripartite division of Angkor civilization gives the impression of rupture, representing different watertight compartments. The truth is that Angkor continues even in 21st century by embedded time-honored practices. Exhausting this theme will be beyond the scope of this short paper. Éric Bourdonneau has already begun this task by attempting to rehabilitate Funan and positing Oc Eo as the first Angkor (Bourdonneau 2007: 111-158.) By placing the theme of cultural continuum I do not mean to say that no change occurred through the course of the Khmer history. There were important and very vital changes, but hey were assimilated by powerful forces of cultural continuum, which is largely responsible for the survival of Khmer as a nation.

In this paper, I propose to see a small anecdote of cultural continuum in space and time from Sambor Prei Kuk to Ak Yom within the time frame of 7th century to 11th century. Prahasiteśvara (Śiva) was the smiling god of Hindu pantheon, presiding over the south group of temples of Sambor Prei Kuk in the 7th century. More serious, profound aspect of Śiva is represented by the god Gambhīreśvara, the serious, profound lord, the presiding deity of the temples of north group.

The following three inscriptions have been found from the archaeological site of Sambor Prei Kuk (Iśanapura) which relate to the Profound Lord (Gambhīreśvara).

- K 439 (Bhavavarman II, 639 A.D.)
- K 436 (10th century)
- K 148 (10th century, temple N15)

K 439, inscribed on the doorjambs of Temple N 20 of Sambor Prei Kuk, mentions King Bhavavarman (stanza III), supposed to be the second king of this name by Cœdès. The only known date of this king is 639 A.D. This king is considered to be the immediate successor of Ishanavarman.

The objective of this fragmentary inscription remains uncertain. It must relate to the god Gambhīreśvara, the main divinity of the temple of North Group. The name of this god appears in the mutilated stanza II of this inscription.

**K 436/ 10th century**

The thirty-four-line Sanskrit language inscription (K 436), engraved at the entrance of the North Group of temples, begins with invocation to Śiva, Nīlakaṇṭha, Viṣṇu Pankajanabha and the four-faced Brahma (I-IV), then mentions the ruling King Rajendravarman (A.D 944-967) and Vikramasiṃha one of the royal servants during this regime (VI-XIII, XXII).

After his return from an expedition against Champa, Vikramasiṃha restored the cult of Gambhīreśvara which must have been the principal divinity of the north group of temples, since the inscription is engraved at the entrance of this complex. He established a foundation at Ishanapuri which led to the installation of this inscription. The above reconstruction has been done from the verses of the inscriptions in which many words are missing:

*XVI:* *Used by the king…by his power, he … the king of Champa… having attacked he ga of Śrī Gambhīreśvara ve all to the king.*

*XX:* *The worship of Śrī Gambhīreśvara has been discontinued…*

*XXI:* *… of Śrī Gambhīreśvara…*

*XXII:* *This Shrimad Vikramasiṃha, who has in the battle the allure of a lion, has made… Īśanapuri…*

**K 148**, engraved on the south doorjamb of temple N15, belongs to the tenth century on the paleographic grounds. The name of Gambhīreśvara figures in one of the mutilated stanzas of the inscription without giving any substantial information about this god.

**Ak Yom**

The step-pyramid of Ak Yom traces the advancing steps of the Profound God from Sambor Prei Kuk to the region of Angkor. The temple is about 12 miles southwest of the Bayon, the central temple of the city of Angkor Thom in the province of Siem Reap. It is at a distance of only 600 meters from the southwest angle of the West Baray. The monument must have been partially buried when the axial road west from the first city of Angkor (Phnom Bakheng) was built in the ninth century. It was perhaps completely engulfed in the 11th century in the dikes of the West Baray. The excavations carried out by Georges Trouvé in 1932 unearthed this monument embedded in the south dike of the West Baray near its southwest corner.

As shown by Philippe Stern, Prasat Ak Yom is a temple central to the pre-Angkorean city which stood once upon a time on the space which is occupied currently by the Lake of West Baray (Glaize: 215). Groslier (1979: 197, map. 2) considers it as one of the principal monuments of the city of Banteay Choeu in the region of Angkor. This city was enclosed by a moat whose northern limit disappeared when the dike of the West Baray was built. The builders of the West Baray tried to protect the temple from being engulfed by water by building a laterite wall between the vast water body and the temple.

In 1933, a three-tiered pyramidal structure with a central tower at the summit emerged out from the excavations of Georges Trouvé. The base of this pyramid descends on the site down to the water level of the Western Baray of Angkor. Like the monuments in Sambor Prei Kuk, Prasat Ak Yom is built entirely in brick with only door frames in sandstone.

The first or the lowermost terrace containing natural earth filling is enclosed by a very thick supporting earthen wall. It is 100 meters square and 2.6 meters high. This terrace has no brick pavement on its top except on the axial causeways. Traces of the stairways are still visible on the north and south sides of this terrace.

The second terrace is accessible by an axial stairway with five steps at each side. It is constituted by a structure lined with bricks, measuring 42 meters on each side and 2.40 meters in height. Its retaining brick wall was seen by the early French explorers decorated with the motif of miniature palaces similar to the early pre-Angkorean art. But they no longer survive due to the vagaries of time. A total of 12 towers—four corner towers and two intermediary towers at each side—were installed at this level according to Glaize (215). But recent plans drawn by Christo shows only 10 towers (Jessup 2004: 63, Bruguier 1994: 273-296). This difference of numbers of towers may be due to the disappearance of two towers as a result of natural vagaries in due course of time after Glaize (12) is a sacred number obtained by the multiplication of cardinal points by three.

The third tier is entire made in brick. The square platform is 17 meter on each side and 1.8 meter in height. At the center of this platform , a brick tower installed on an elevated base goes back to the original lay out of the sanctuary. At the time of the construction of the southern dike

of the West Baray, the central tower was protected by a supporting wall in laterite in the north and by a building in laterite along the eastern side.

The central tower at the summit underwent at least two modifications. Originally it was open to the east only. Later the openings were made in the northern, southern and western walls of the tower and the walls were doubled at the interior and exterior by the supportive wall in brick. The modifications carried out at the site are of uncertain date. Jean Boisselier thinks that the absence of corner pilaster at the retaining wall of central tower suggests that they are not earlier than the 10$^{th}$ century A.D. (Boisselier cited by Bruguier 1994: 273-296).

The cella of the central temple at the summit of the pyramid is a square chamber measuring 5.50 m at each side. A pedestal, provided with a channel to drain out water, must have served the seat of the divinity which was not recovered from the site. The pedestal probably carried a linga.

Near the western door was found a bull, Nandin and a decorated piece of stone. A small head (7 cm in height) was recovered from the southeast corner of the cella. Five Buddhist figures in bronze (measuring between 35 and 9 cm) were hidden above the northern door of the central cell behind the decorative lintel. The sixth found at the base of the door must have been concealed at the same place. These images represent Maitreya and Avalokitesvara. The near total absence of stone sculptures from the site seems to be due to the fact they were transferred to the neighboring monastery of Wat Khnat. (Georges Trouvé, *op.cit.*: 1130).

Majority of the lintels and colonnettes recovered from Ak Yom belong to the central tower. The lintels of the northern and southern sides are decorated with a polylobed arch divided into four segments. They are ornamented with pendants and garlands and belong to the style of Prei Kmeng, a monument in the neighborhood of Prasat Ak Yom.

In the words of Maurice Glaize the ornamentation of Ak Yom provides some rare evidence of pre-Angkor art, akin to Sambor Prei Kuk, described as the primitive art by the earlier generation of French scholars. The lintels, often reused are slim in height and simplistic in composition. Some incorporate medallions and pendants, others branches and terminal scrolls with an invasion of foliage. The colonnettes are cylindrical with a relatively charged ornamentation of beads and leave on the ring. The "hipped" devatas sculpted in brickwork are still visible on the southern sanctuary, where there is also remarkable false door on the east side. On the panels, small lions in circular medallions are set on band of leaves in a crossing motif (Glaize*, op.cit.* p. 216).

Two pre-Angkorean Khmer inscriptions (K 749 and K 753) are inscribed on the door-jambs, reused in the central sanctuary of Ak Yom. K 749 is inscribed in big letters on the south door jamb of the east door of the central temple. The text consists of 15 lines in Khmer language. The text begins with a date X39, in which the first numeral figure, representing the digit for hundred is not clear It may correspond to 539 or 639 śaka era (617 or 717 A.D.) according to Cœdès. According to another supposition the date should correspond to A.D. 674 (Vickery: 128, fn 150). The date of 539 śaka (617 A.D.) is generally not retained since it would be much earlier than the first use

of decimal numbering where the value is determined by the position of each numeral figure. However, we do not have any evidence to clearly establish that the decimal figure was not used in the first decade of seventh century. The text uses the title of *mratāñ* which was prevalent in the time of Ishanavarman. The concept of satra was also in vogue by this time. In fact the text mentions the foundation (*kalpita satra*) of a certain Mratāñ Kīrttigaṇa at (the temple of) the god (*vraḥ kamrateṅ āñ*) Śrī Gambhīreśvara. It lists the slaves the founder offered to Harigana, Harivahana and Tan Gay the caretakers of the temple. Finally the text states that all these means of subsistence (*upāya*) and the children of Mratāñ Kīrttigaṇa are in the service of *vraḥ kamrateṅ āñ* śrī Gambhīreśvara.

Yet another pre-Angkorean inscription (K 753) is engraved on the eastern doorjamb of the south door of central temple of Ak Yom. The Khmer inscription of 25 lines bear the date 626 śaka (704 A.D.) and lists the donations of a number of *mratāñ* to several gods. Names of the gods, except Yuddhesvara are lost in the mutilated text. So are the names of donors whose title mratāñ only survives.

An inscribed stone slab (K 752), bearing one line in Khmer language, was found in the southeastern building. The text informs us that in 923 śaka (1001 A.D.), on a Sunday , the first day of the waxing moon of Asvayuja in Chitra nakshatra this (sacred stone piece with figures of nine planets) was given to *vraḥ kamrateṅ āñ* śrī Gambhīreśvara by Steṅ añ who practices asceticism.

The transition from a single-chambered brick sanctuary to multiple towers on top of a raised series of platforms probably took place at Ak Yom. The temple is a forerunner of a true five towered pyramid. The relationship of the central tower to the towers at the sub-cardinal points of the second level" observes Jessup, " presages the five-tower quincunx form, with towers at the corner enclosing a central tower, that was to be developed more dramatically during the next four centuries in Bakheng, Pre Rup, Ta Keo and Angkor (Jessup 2004: 64).

The hypothesis that Jayavarman II commissioned Ak Yom as "a lesser prototype " of the temple mountain is based on the circumstantial evidence regarding coming of the king from the island of Java where he is supposed to have been impressed by the mountain metaphor of architecture and polity" (Rawson 1967: 50).

As Bruno Bruguier suggests there is absolutely no ground to subscribe to the view that Ak Yom corresponds to one of the temples built by Jayavarman I on the site of Purandarapura (Jacques 1988: 28-32). Nor it is possible to confirm that it corresponds to one of the royal residences of Jayavarman II mentioned in the inscription of Sdok Kak Thom: Indrapura or Amarendrapura as proposed by George Trouvé and Philippe Stern. His analysis of Ak Yom leads Bruno Bruguier (*op. cit.*: 284) to conclude that "the architectural form known as the temple-mountain pre-dates the cult of devaraja inaugurated by Jayavarman II on Mount Kulen at Prasat Rong Chen"

When the five-mile long water reservoir with its associated canals was built in in the $11^{th}$ century to the west of Angkor, it submerged the pre-existing city under it and covered the old Ak Yom with its dyke. A stone slab, bearing an inscription (K 904), was virtually recovered from

the depth of the water reservoir of the West Baray on 30th July 1939 by Maurice Glaize. The inscription was found deteriorated since the stone slab might have remained under water for a long time. According to this text in 713 A.D. Queen Jayadevi was ruling in this area though she was afflicted by the vagaries of the prevailing times(*kilstapi kalikalena*) She made donation to a temple of Shiva Tripurantakeśvara founded by an Indian Brahmin Sakrasvamin and his Khmer wife Princess Sobhajaya (*IC* IV: 54). Bruno Bruguier places the construction of Ak Yom in eight century before the establishment of Angkorean royalty in 802 at Phnom Kulen. However the chronological indicators furnished by inscriptions (K 749 and K K 753 and the stylistic considerations of feminine figures and ornamentation leads Glaize (215) to suggest that the monument started in the seventh century, but did not take final form until the beginning of ninth century.

Two pre-Angkorean inscriptions from the site do not definitely date the present shape of the temple to the time of these texts, since these pieces are re-used at a later date. However, Glaize seems to be nearer to the truth while stating that the stylistic considerations of feminine figures and ornaments suggest that the monument started in the 7th century, but did not take final form until the beginning of the ninth century.

An early date for K 749 is possible if we agree to read śaka year X39 as the 539 śaka ( 617 A.D.) which corresponds to the reign of Ishanavarman. Ruling out the possibility of the use of decimal numbering in the beginning of the seventh century is arbitrary. The decimal number with the use of zero was in use the Old Khmer inscription of Sambor (Trapeang Prei, K 127), giving us the śaka year 605 corresponding to A.D. 683 (Cœdès 1931: 323-328). There is no reason to believe that the decimal system had not reached Cambodia a few decades before K 749 in 617 A.D. The testimony of Glaize clearly suggests that Ak Yom was a monument of early pre-Angkor era, so far its ornamentations and motifs are concerned. At present the site is so deteriorated that what was seen by the colonial French scholars are no longer visible.

It is also to be noted that the diffusion of the cult of Gambhīreśvara. The foregoing analysis suggests that the region between Sambor Prei Kuk and Ak Yom, representing the present-day province of Kampong Thom and Siem Reap was part of cultural zone of Gambhīreśvara.

Issued by the Adhyapura (Ba Phnom) family of royal officials, The Sanskrit inscriptions K 53, dated 667 A.D. is one of the rare long family records of pre-Angkor Cambodia. The record mentions four generations of officials who served five kings including Ishanavarman and his successor Jayavarman I. Referring to Bhavavarman I the text declares that the god Gambhīreśvara was "the fruit of his reign. The earliest known date of Bhavavarman I is 598 A.D. There is no reason to believe that the Adhyapura family was not in a position to remember and record correctly the religious situation of the country as part of recent history. On this basis of this record we can postulate that the god Gambhīreśvara was known up to the region of Ba Phnom in Southern Cambodia. Certainly we are not dealing with a god localized in the region of Sambor Prei Kuk.

No inscription mentioning Gambhirshvara in relation to Ishanavarman has survived.

However, as we have noted in the foregoing analysis, both his predecessor (Bhavavarman I) and successor (Bhavavarman II) are mentioned in the context of Gambhīreśvara. Therefore, patronage of Īśanavarman to the god Gambhīreśvara could not be contested.

**The Indian Sources for Gambhīreśvara**

The epithet of Gambhira "profound", unfathomable is given to Shiva in the Mahābhārata (XIII, 1167) and *Śiva Purāṇa* IV: 35, 46. The Mahābhārata describes Shiva as *gambhiraghosho gambhiro gambhirabalavahanah*; the one who has a profound voice, who is unfathomable and whose force and mount are unfathomable. Commenting on this passage Nīlakaṇṭha says that the mount of Śiva, the Bull is unfathomable because he symbolizes the Dharma, the Law or the Cosmic Order. In the light of these citations, it is difficult to maintain with H.Q. Quaritch Wales that Gambhīreśvara signifies "Śiva of the Depths" ( Quaritch Wales 1957: 130 cited by Bhattacharya Kamaleshwar).

An under-ground chamber below the sanctum sanctorum of Ak Yom was found 40 feet below the surface level. At that level in a vaulted brick chamber sacred deposits such as two leaves of beaten gold with figures elephant and five small pieces of polished stones were found deposited. According to Bruno Dagens the idea of the depth expressed in the passage of the Mahābhārata should be placed in relation to the underground chamber found at the depth of the well in the center of the pyramid of Ak Yom. This hypothesis is, however, not tenable since soon after this discovery central pit was found in the temple of Bayon also. This practice is part of the ritual of foundation of temple. The god Śiva does not represent as Gambhīreśvara the physical idea of depth, length or width. He is simply Gambhīra Īśvara, the Profound (Gambhīra) Lord (Īśvara), radiating his serious, profound nature (Bruguier 1994: 273).

**REFERENCES**

Bhattacharya, Kamaleshwar. 1961 *Les religions brahmqniques du Cambodge ancien*. EFEO: Paris.

Boisselier, Jean. Cours manuscrit sur le Prasat Ak Yum", 12 pages, cited by Bruno Bruguier, *op. cit*, 273-296).

Bourdonneau, Éric. 2007 *Réhabiliter le Funan Óc Eo ou la première Angkor. BEFEO*, 94: ???.

Bruguier, Bruno.1994 "Prasat Ak Yum, etat des connaissance" in F. Bizot (ed.), Nouvelles Recherches sur le Cambodge, EFEO.

Cœdès, George. 1931. "A propos de l'origine des chiffres arabes" BSOAS, 6:323-328.

Glaize, Maurice. *The Monuments of the Angkor Group*, a translation from the 4th French edition (n.d.).

Groslier, Bernard Philippe. 1979. "La cite hydrolique angkorienne. Exploitation ou sur exploitation du sol", *BEFEO.*

Jacques, Claude. 1988. "Le pay Khmer avant Angkor. *Dossier Histoire et archeology*, 125, Dijon, (pp.

28-32)"

Jessup-Ibbitson, Helen. 2004. *Art and Architecture of Cambodia*. London: Thames & Hudson.

Quaritch Wales, H.G. 1957 *Prehistory and Religion in South-East Asia*, London.

Rawson, Philip. 1967. *The Art of Southeast Asia.* London: Thames and Hudson.

# កិច្ចការអភិរក្ស និងជួសជុលប៉មឥដ្ឋលេខ១៨ ប្រាសាទឥដ្ឋបាគង

*តាន់សុផល*
*អាជ្ញាធរជាតិអប្សរា*

## ស្ថានភាពប្រែឈម

*នៅចន្លោះកសិន្ធុទឹកខាងក្រៅនិងខាងក្នុងនៃប្រាសាទបាគង មានរចនាសម្ព័ន្ធប៉មឥដ្ឋចំនួន៣៩ សង់លាតសន្ធឹងតាមលំដាប់រៀងលើទីតាំងដោយឡែកៗ( ប្លង់១ ) ក្នុងនោះប៉មខ្វះសេសសល់តែទ្រង់ទ្រាយ គេអាចសន្និដ្ឋានបានថាជាសំណង់ប្រាសាទអំពីឥដ្ឋលាយជាមួយថ្មភក់និងថ្មបាយក្រៀម ប៉ុន្តែស្ថិតក្នុងភាពខូចខាតធ្ងន់ធ្ងរ។ រីឯទីតាំងមួយចំនួនទៀតនៅកសិន្ធុទឹកទីពីរផ្នែកខាងក្រៅជ្រុងអាគ្នេយ៍ ( ចំណុចលេខ៣៤នៃប្លង់១) ពុំបង្ហាញរូបរាងសំណង់ច្បាស់លាស់ ដើម្បីប្រាប់ឲ្យដឹងអំពីទម្រង់របស់ប៉មឥដ្ឋ ពិសេសបំណែកដុំឥដ្ឋទាំងឡាយនៅលើផ្ទៃដីក៏ពុំមានសេសសល់ឡើយ។ បើប្រៀបធៀបរចនាសម្ព័ន្ធប៉មឥដ្ឋចំនួនបីទីតាំងស្ថិតនៅជ្រុងកែងដូចគ្នានៃសិន្ធុទឹកទីពីរផ្នែកខាងក្រៅ គឺប៉មជ្រុងនិរតីត្រង់ចំណុចលេខ៣៥(រូប១) ទៅនឹងប៉មឥដ្ឋពាយ័ព្យចំណុចលេខ៣៩និងប៉មឥដ្ឋជ្រុងឦសានចំណុចលេខ៣៣(រូប២) គេអាចពិនិត្យដឹងអំពីរូបរាងព្រាលៗរបស់សំណង់ ដែលបានរងការខូចខាតតាមស្ថានភាពខុសៗគ្នា។*

*បច្ចុប្បន្នស្ថានភាពប៉មឥដ្ឋទាំងអស់ពុំមានន័យថា ធានាទូវភាពរឹងមាំគ្រប់គ្រាន់ឡើយ ចំណែកកិច្ចការយកចិត្តទុកដាក់លើផ្នែកអភិរក្សនិងជួសជុលឥដ្ឋ ក៏ពុំទាន់បានសង្គ្រោះដល់រចនាសម្ព័ន្ធទាំងមូលគ្រប់ជ្រុងជ្រោយនៅឡើយ។ នៅកំឡុងឆ្នាំ១៩៣២ សាលាបារាំងចុងបូព៌ា (EFEO)បានធ្វើការអន្តរាគមន៍និងសង្គ្រោះបឋមៗដល់ផ្នែកខូចខាតខ្លះៗនៅជុំវិញប្រាសាទបាគងដូចជា៖ ត្រួសត្រាយព្រៃបរិវេណជុំវិញប៉មធ្វើកំណាយស្រាវជ្រាវសម្អាតកំណកដី ព្រមទាំងទល់ទ្រផ្នែកដទៃទៀតដោយប្រើប្រាស់ទ្រនល់បេតុង។*




ប្លង់១៖ ប្លង់LiDAR ឆ្នាំ២០១៩ បង្ហាញអំពីសំណង់ឥដ្ឋជុំវិញប្រាសាទ



រូប១៖សំណល់គ្រឹះនៃប៉មឥដ្ឋជ្រុងនិរតី



រូប២៖ទ្រង់ទ្រាយនៃប៉មឥដ្ឋជ្រុងឥសាន

Results of the performed theoretical simulations, provided so far, may be fundamental for understanding the principles of a structural behaviour of Angkor monuments. The study documented that the temperature changes represent significant factor negatively affecting the technical state of temple structures. Based on these results it was possible to describe some causes and processes that may be responsible for the disintegration of temple structures. Theoretical models can be used also in the future for studying reaction of the monuments to other types of load effect and for forecasting possible development of their future structural and static reliability. Moreover, with theoretical models, it will be possible to analyse in detail the consequences of historical construction interventions and to test the future interventions focused on elimination or more precisely remediation of structural lacks and defects of the monument structures or at least to preserve the present state.

Given the results obtained so far in cooperation with the Apsara Authority it became possible to formulate some recommendations for performing future reconstructive interventions of the relevant structures. In cooperation with Apsara Authority, it is hoped that CNPA will be able to further develop and test these models.

## References

Dlubal Software Ltd., Program RFEM, Prague, 2012.

Pasek, J., Kranda, K., Svoboda, J., Gaya, H. P., (Extant Analysis and Evaluation of the Observed Structural Faults and Failures in Standing Constructions of Angkor. unpublished lecture. 21st Technical Session of International Coordinating Committee for the Safeguarding and Development of the Historic Site of Angkor Meeting, (ICC), Siem Reap, June 2012.

Pasek, J., Gaya, H.P., Numerical simulations of the influence of temperature changes on structural integrity of stone temples in Angkor, Cambodia, in: *Applied Mathematics and Computation* 267. Elsevier. 2015: 409 – 418.

Kranda, K., Pasek, J., Svoboda, J., Gaya, H. P., Time-resolved Thermo-imaging of Sandstone Structures, ICC – Angkor Conference, Siem Reap, December 2009.

Siedel, H., Pfefferkorn, S., Von Plehwe-Leisen, E., Leisen, H., Sandstone weathering in tropical climate: Results of low-destructive investigations at the temple of Angkor Wat, Cambodia, *Engineering Geology* 115. Elsevier. 2010: 182 – 192.

Uchida, E., Cunin, O., Suda, C., Ueno, A., Nakagawa, T, Consideration on the construction process and the sandstone quarries during the Angkor period based on the magnetic susceptibility, *Journal of Archaeological Science* 34.Elsevier. 2007: 924 – 935.

Uchida, E., Ogawa, Y., Maeda, N., Nakagawa, T., Deterioration of stone materials in the Angkor monuments, Cambodia, *Engineering Geology* 55, Elsevier. 1999: 101 – 112.

# ប្រព័ន្ធធារាសាស្ត្រនៃឧទ្យានអង្គរ

*ហង់ ពៅ*
*អគ្គនាយកអាជ្ញាធរជាតិអប្សរា*

*ការគ្រប់គ្រងទឹកបានយ៉ាងប្រសើររបស់វិស្វករខ្មែរនៅសម័យបុរាណត្រូវបានឆ្លុះបញ្ចាំងតាមរយៈ រចនាសម្ព័ន្ធធារាសាស្ត្រជាច្រើនស្មុគស្មាញនៅអង្គរមានដូចជាបារាយណ៍ កសិន្ធុទឹក ទំនប់ធ្វើពីថ្មបាយក្រៀម ស្ពាន អាងទឹក អូរ និងប្រឡាយតូចធំជាដើម។*

*ដោយសារមូលហេតុនៃកំណើនចំនួនភ្ញៀវទេសចរកើនរៀងរាល់ឆ្នាំ និងកំណើនចំនួនប្រជាជននៅក្នុង តំបន់សៀមរាបទាំងមូលតម្រូវការផ្នែកទឹកក៏កាន់តែកើនឡើងខ្លាំងណាស់ដែរ ដែលធ្វើអោយការងារគ្រប់គ្រង ទឹកនៅក្នុងតំនប់សៀមរាបអង្គរក្លាយជាបញ្ហាដ៏ធំចំពោះការអភិរក្សប្រាង្គប្រាសាទ និងការអភិវឌ្ឍ ន៍ប្រកបដោយ ចីរភាព។ បញ្ហាប្រឈមគឺត្រូវធ្វើយ៉ាងណាឆ្លើយតបអោយបានទាន់ពេលចំពោះតម្រូវការទឹកប្រចាំថ្ងៃ ហើយ ទន្ទឹមនឹងនោះក៏ត្រូវប្រុងប្រយ័ត្ន ធានាអោយបានស្ថេរភាពចំពោះប្រាង្គប្រាសាទអង្គរដែលសាងសង់នៅលើ គ្រឹះខ្សាច់ ហើយពាក់ព័ន្ធទៅនឹងស្រទាប់ទឹកក្រោមដី។*

*នាយកដ្ឋានគ្រប់គ្រងទឹករបស់អាជ្ញាធរអប្សរាបានធ្វើការងារត្រៀមរៀបចំផ្នែកទ្រឹស្តី និងអនុវត្តជាក់ស្តែង ចាំបាច់នានាក្នុងការស្តារប្រព័ន្ធធារាសាស្ត្របុរាណក្នុងសម័យអង្គរ ដើម្បីធ្វើអោយតួនាទីដ៏សំខាន់នៃប្រព័ន្ធ ទឹកទាំងនោះដំណើរការឡើងវិញក្នុងការអភិរក្សប្រាង្គប្រាសាទ និងចូលរួមជាផ្នែកមួយនៃទេសភាពវប្បធម៌ និង បរិស្ថានឧទ្យានជាទូទៅ។ កម្មវិធីនេះពិតជាត្រូវអនុវត្តដោយប្រើពេលវែង និងលំបាក ហើយយើងអាចអនុវត្ត បានក៏ដោយសារមានបច្ចេកទេសនិងហិរញ្ញវត្ថុរបស់អាជ្ញាធរប្សរាដែរ។ គម្រោងនេះផ្តោតជាពិសេសលើការ ប្រៀបធៀបរវាងការវិភាគ និងសេចក្តីសន្និដ្ឋានដំបូង និងទិន្នន័យដ៏សំបូរបែបដែលមិនធ្លាប់មានពីមុនមក ដោយសារ ទឹកជំនន់នៅឆ្នាំ២០០៩ ឆ្នាំ២០១០ និងឆ្នាំ២០១១។*



កសិន្ធុទឹកខាងជើងផ្លូវខាងលិច និងផ្លូវចូលអង្គរវត្ត



ប្រាសាទនាគព័ន្ធនៅចំកណ្ដាលអាងទឹក

## ការស្តារឡើងវិញនូវរចនាសម្ព័ន្ធធារាសាស្ត្របុរាណ

កិច្ចការសំខាន់ដែលត្រូវធ្វើដំបូង មុននឹងអាចចាប់ផ្តើមការងារស្តារឡើងវិញនោះ គឺវិភាគជាទឹក តាំងពីកន្លែងប្រភពដើមដែលចេញពីអាងផ្ទុកទឹកនៅលើភ្នំគូលែន រហូតដល់កន្លែងដែលទឹកហូរទៅចាក់នៅក្នុងបឹងទន្លេសាប ដែលនៅតាមផ្លូវនោះ ទឹកហូរទៅក្នុងអាងផ្ទុកទឹកចំនួនបី គឺមានស្ទឹងពួកនៅខាងលិច ស្ទឹងសៀមរាបនៅកណ្តាល និងស្ទឹងរលួសនៅខាងកើត។ មើលទៅស្ទឹងពួក និងរលួសគឺដូចជាស្ទឹងដែលកើតមានតាមធម្មជាតិ ចំណែកឯស្ទឹងសៀមរាបគឺដូចជាផ្លូវទឹកសិប្បនិមិត្ត មានន័យថាជាផ្លូវទឹកដែលគេបង្កើតឡើង ដើម្បីត្រងយកទឹកភ្លៀងដែលហូរចេញមកពីភ្នំគូលែន ដោយឆ្លងកាត់អាងចំរោះបំពេញរាជ ដែលធ្វើអំពីថ្មបាយក្រៀម មានទទឹង៦០ម៉ែត្រ និងបណ្តោយ៣០០ម៉ែត្រ កសាងឡើងនៅចុងសតវត្សទី៩។

ដោយសារលទ្ធផលនៃការស្រាវជ្រាវជាក់ស្តែងស្តីអំពីប្រព័ន្ធធារាសាស្ត្របុរាណអស់រយៈពេលជាង៨ឆ្នាំកន្លងមក ធ្វើឡើងដោយនាយកដ្ឋានគ្រប់គ្រងទឹក រចនាសម្ព័ន្ធបុរាណមួយចំនួនដែលបានកសាងឡើងក្នុងសម័យអាណាចក្រខ្មែរអង្គរ ដោយវិស្វករធារាសាស្ត្រ ត្រូវបានជួសជុលឡើងវិញជាស្ថាពរ។

## ស្រះស្រង់

ស្រះស្រង់មានទឹកដោយសារទឹកភ្លៀង និងទឹកជ្រាបពីក្រោមដី ចេញពីបារាយណ៍ខាងកើត និងទឹកក្រោមដីដែលនៅជុំវិញស្រះនោះ។ ប៉ុន្តែដោយសារបារាយណ៍ខាងកើតរីងស្ងួតហួតហែងអស់ទៅហើយ និងដោយសារការកម្រិតទឹកក្រោមដីបានស្រកចុះ  ទឹកក្នុងស្រះស្រង់ក៏បានចាប់ផ្តើមរីងស្ងួតដែរនៅរដូវប្រាំងរហូតដល់គ្មានទឹកទាល់តែសោះនៅខែមេសា ឆ្នាំ២០០៤។ នៅខែមីនាឆ្នាំ២០០៥ នាយកដ្ឋានគ្រប់គ្រងទឹកបានរៀបចំបង្កើតប្រព័ន្ធបន្ថែមមួយដើម្បីបង្ហូរទឹកចូលក្នុងស្រះស្រង់ ដោយយកទឹកចេញពីម្តុំភ្នំបូក និងរលួស។

## កសិន្ធុទឹកអង្គរធំ

អាងដ៏ធំមួយនេះ  អាចផ្ទុកទឹកបានជិត២លានម៉ែត្រគូប  វាជាកសិន្ធុទឹកដែលមានប្រវែង១២គីឡូម៉ែត្រព័ទ្ធជុំវិញកំផែងក្រុងអង្គរធំ។  កាលពីពេលថ្មីៗនេះ  មានតែកសិន្ធុទឹកផ្នែកខាងត្បូងឈៀងខាងលិចប្រមាណ៣០០០ម៉ែត្រប៉ុណ្ណោះដែលមានទឹក  ខណៈដែលផ្នែកខាងត្បូងឈៀងខាងកើតនៃកសិន្ធុ  គ្មានទឹកទៀតឡើយនៅរដូវវស្សា។  បន្ទាប់ពីយើងបានធ្វើការជួសជុលរួចមក  ចាប់តាំងពីឆ្នាំ២០១០  កំណាត់នៃកសិន្ធុខាងត្បូងឈៀងខាងកើតប្រវែង៣០០០ម៉ែត្រ មានទឹកជាប្រចាំពេញមួយឆ្នាំៗ ទាំងក្នុងរដូវប្រាំង និងរដូវវស្សា ហើយឆ្នាំ២០១២ កសិន្ធុទឹកទាំងមូលប្រវែង១២គីឡូម៉ែត្រក៏មានទឹកជាប់ជាប្រចាំឡើងវិញសារជាថ្មី។

## កសិន្ធុទឹកប្រាសាទអង្គរវត្ត

មុខឆ្នាំ២០១០ ប្រព័ន្ធបង្ហូរទឹកបំពេញកសិន្ធុទឹកប្រាសាទអង្គរវត្តគឺមានប្រឡាយមួយដែលគេកសាងឡើងនៅចន្លោះកសិន្ធុទឹកអង្គរធំខាងត្បូងឈៀងខាងលិចរហូតដល់ត្រពាំងសេះ ធ្វើងកាត់ខាងក្រោយកន្ទែងបង្ហោះបាឡុងក្នុងសម័យថ្មីនេះ។ បច្ចុប្បន្ន យើងបានស្តារប្រព័ន្ធបុរាណឡើងវិញ ដោយភ្ជាប់កសិន្ធុទឹកអង្គរធំផ្នែកខាងត្បូងឈៀងខាងកើតទៅកសិន្ធុទឹកអង្គរវត្តផ្នែកខាងជើងឈៀងខាងលិចផ្ទាល់ ដោយធ្លងកាត់តាមកសិន្ធុទឹកក្នុបាខែង និងអូរសំពៅលូន។ ប្រព័ន្ធនេះបានធ្វើអោយកម្រិតទឹកក្នុងកសិន្ធុអង្គរវត្តកើនបានកម្ពស់១ម៉ែត្របើប្រៀបធៀបទៅនឹងកម្រិតទឹករបស់វានៅពេលមុន។

## បារាយណ៍ខាងជើង (ជ័យតដាក)

បារាយណ៍នេះមានបណ្តោយ៣៦០០ម៉ែត្រ និងទទឹង៩៣០ម៉ែត្រ និងមានសមត្ថភាពផ្ទុកទឹកពីដំបូងបានរហូតដល់៥លានម៉ែត្រគូប។ ទឹកនៅក្នុងបារាយណ៍នេះមិនត្រូវបានគេប្រើដើម្បីយកទៅស្រោចស្រពដំណាំដូចទឹកបារាយណ៍ផ្សេងទៀតនៅក្នុងតំបន់នេះឡើយប៉ុន្តែគេរក្សាទឹកក្នុងបារាយណ៍នេះសម្រាប់ប្រើក្នុងក្រុងអង្គរធំប្រាសាទព្រះខ័ន និងមន្ទីរពេទ្យនាគព័ន្ធ។ បារាយណ៍នេះបានរីងស្ងួតហួតហែងអស់ជាង៥០០ឆ្នាំមកហើយ ម្យ៉ាងវិញទៀតអ្នកស្រាវជ្រាវមួយចំនួនគិតថា ការធ្វើអោយបារាយណ៍ខាងជើងនេះមានទឹកសារជាថ្មីឡើងវិញ នឹងអាចទៅរួចនោះឡើយ។ ប៉ុន្តែនៅឆ្នាំ២០០៧ អ្នកស្រាវជ្រាវខ្មែរបានជួសជុលប្រព័ន្ធបង្ហូរទឹកដែលគេបានរកឃើញនៅឆ្នាំ២០០៥ ហើយនៅឆ្នាំ២០០៨ ទឹកក៏ចាប់ផ្តើមហូរចូលក្នុងបារាយណ៍នេះវិញ។ ការបង្ហូរទឹកចូលបំពេញក្នុងបារាយណ៍ខាងជើងត្រូវបានធ្វើឡើងដូចតទៅនេះៈ ចំនួន៧០០០០០ម៉ែត្រគូបនៅឆ្នាំ២០០៨ ចំនួន៣០០០០០០ម៉ែត្រគូបនៅឆ្នាំ២០០៩ ចំនួន៣៦៧៨០០០ម៉ែត្រគូបនៅឆ្នាំ២០១០ និងចំនួន៥០០០០០០ម៉ែត្រគូបនៅឆ្នាំ២០១១ និងឆ្នាំ២០១២។

## នាគព័ន្ធ

នាគព័ន្ធគឺជាប្រាសាទនៅលើកូនកោះតូចមួយ ចំកណ្តាលបារាយណ៍ខាងជើងប្រៀបដូចជាប្រាសាទមេបុណ្យក្នុងបារាយណ៍ផ្សេងទៀតដែរប៉ុន្តែនៅសម័យបុរាណនាគព័ន្ធមានមុខងារផ្សេងមួយទៀតគឺថាវាជាមន្ទីរពេទ្យដែលប្រើប្រាស់រុក្ខជាតិជាឱសថបុរាណ។ នៅជុំវិញប្រាសាទនេះមានអាងតូចៗចំនួន៤ ដែលនៅក្នុងសម័យក្រោយមកបានរីងស្ងួតអស់ពេញមួយឆ្នាំៗ លើកលែងតែអាងកណ្តាលដែលមានទឹករយៈពេលតែប៉ុន្មានខែប៉ុណ្ណោះក្នុងមួយឆ្នាំ នៅរដូវវស្សា។ ប៉ុន្តែចាប់តាំងពីបារាយណ៍ខាងជើងមានទឹកសារជាថ្មីឡើងវិញមក អាងទាំងប្រាំនេះក៏មានទឹកពេញឡើងវិញគ្រប់រដូវដែរ។ អាងទាំងនេះដែលភ្ជាប់ទៅនឹងបារាយណ៍ខាងជើងគឺជាការឆ្លុះបញ្ចាំងយ៉ាងល្អជាងគេ អំពីប្រព័ន្ធធារាសាស្ត្រនៅក្នុងឧទ្យានអង្គរដែលត្រូវបានចុះនៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

## ប្រាសាទព្រះខ័ន

*នៅក្នុងសម័យបុរាណ ដូចស្រះស្រង់ដែរ កសិន្ធុទឹកប្រាសាទព្រះខ័នគ្មានប្រព័ន្ធទឹកបង្ហូរចូលបំពេញនោះទេ។ នៅសម័យបច្ចុប្បន្នកសិន្ធុនេះមានទឹកតែក្នុងមួយរយៈពេលណាប៉ុណ្ណោះក្នុងមួយឆ្នាំ ប៉ុន្តែតាំងពីបារាយណ៍ខាងជើងមានទឹកសារជាថ្មីឡើងវិញមក កសិន្ធុប្រាសាទព្រះខ័នក៏មានទឹកឡើងវិញពេញមួយឆ្នាំដែរ។ បាតុភូតនេះបង្ហាញថា បារាយណ៍ខាងជើង និងព្រះខ័នមានទំនាក់ទំនងគ្នាតាមរយៈទឹកក្រោមដី ប៉ុន្តែវាក៏បង្ហាញផងដែរថា កសិន្ធុប្រាសាទព្រះខ័នដែលមានទឹកឡើងវិញនេះ គឺជាលទ្ធផលនៃការកើនឡើងនៃកម្រិតទឹកក្រោមដី ដោយសារតែបារាយណ៍ខាងជើងមានទឹកឡើងវិញសារជាថ្មី។*



*ទស្សនីយភាពប្រាសាទព្រះខ័ន*

## បារាយណ៍ខាងលិច

*នៅក្នុងទសវត្សឆ្នាំ៦០ ដើម្បីបំពេញទឹកក្នុងបារាយណ៍ខាងលិច ទឹកស្ទឹងសៀមរាបត្រូវបានគេបង្វែរទៅនៅត្រង់ជ្រុងខាងជើងឈៀងខាងកើតនៃក្រុងអង្គរធំ តាមរយៈអូរមួយដែលគេកសាងឡើងនៅខាងក្នុងកសិន្ធុអង្គរធំតែម្តង ( កសិន្ធុខាងជើង និងខាងជើងឈៀងខាងលិច) មានបណ្តោយប្រវែង៤៥០០ម៉ែត្រ ភ្ជាប់ទៅនឹងអូរមួយនៅតាមបណ្តោយផ្លូវចូល ដោយឆ្លងកាត់តាមក្លោងទ្វារតាការ ដែលជាក្លោងទ្វារខាងលិចនៃអង្គរធំ។អូរទាំងនេះមានមុខងារបញ្ចៀសទឹកចេញពីផ្នែកនេះនៃកសិន្ធុនិងផ្នែកខាងកើតនៃបារាយណ៍ខាងលិចខណៈដែលកន្ទងមក ជាទូទៅគេគិតថា កង្វះទឹកគឺបណ្តាលមកពីមានដីកកនៅក្នុងបារាយណ៍។ នៅឆ្នាំ២០១០ នាយកដ្ឋានគ្រប់គ្រងទឹកបានរកឃើញប្រព័ន្ធបង្ហូរទឹកបំពេញនៅក្នុងបារាយណ៍ខាងលិចពីសម័យ*

ដើម ដែលនៅក្នុងនោះមានអាងច្រោះទឹកបុរាណមួយ និងអូរមួយលាតសន្ធឹងដល់ជ្រុងខាងជើងឈៀងខាងលិចនៃកសិន្ធុអង្គរធំ។ នៅឆ្នាំ២០១១ អាជ្ញាធរអប្សរាបានបើកអូរសម័យដើមបង្ហូរទឹកបំពេញបារាយណ៍ខាងលិច ដើម្បីស្រូបយកភ្លៀង និងការពារអ្នកស្រុក។ នៅឆ្នាំ២០១២ អាជ្ញាធរអប្សរាបានស្តារប្រព័ន្ធបង្ហូរទឹកបំពេញបារាយណ៍ទាំងមូលឡើងវិញ ហើយសព្វថ្ងៃបារាយណ៍ខាងលិចអាចមានទឹកពេញផ្ទៃរបស់វា បែបនេះវាដើរតួយ៉ាងពេញទំហឹងនៅក្នុងការគ្រប់គ្រងទឹកភ្លៀង។

## ការការពារភាពរាំងស្ងួតនិងទឹកជំនន់

គ្មានសិលាចារឹកនៅសម័យអាណាចក្រខ្មែរណាមួយដែលនិយាយអំពីទឹកជំនន់ ឬភាពរាំងស្ងួតនៅក្នុងតំបន់អង្គរឡើយ។ ប្រជាជនខ្មែរក៏មិនបានផ្ទេរពីជំនាន់មួយទៅជំនាន់មួយតាមរយៈរឿងព្រេងនិទាននូវការចងចាំអំពីគ្រោះធម្មជាតិណាមួយនោះដែរ។ ដូច្នេះ គេហាក់ដូចជាមានអារម្មណ៍ថា បញ្ហាទាំងនេះមិនបានកើតមានឡើងនៅក្នុងអតីតកាលទេ បញ្ជាក់ថា ប្រព័ន្ធគ្រប់គ្រងទឹកនៅក្នុងសម័យបុរាណអាចមានលទ្ធភាពគ្រប់គ្រងធនធានទឹកបានយ៉ាងប្រសើរបំផុត។ ប៉ុន្តែ ដោយសារប្រព័ន្ធទឹកបុរាណមិនដំណើរការអស់រយៈពេលយូរពេកនោះ នៅឆ្នាំ២០០៤ យើងបានជួបប្រទះភាពរាំងស្ងួតនៅក្នុងកសិន្ធុអង្គរវត្ត ស្រះស្រង់ក៏រីងទឹកអស់ បន្ទាប់មកមានទឹកជំនន់នៅឆ្នាំ២០០៩ ឆ្នាំ២០១០ និងឆ្នាំ២០១១។

គេអាចយល់បានដោយចាប់ផ្តើមពីការពិនិត្យមើលជារទឹកនៅនឹងកន្លែងផ្ទាល់តែម្តង ដោយស្វែងរកអូរផ្សេងៗនិងបណ្តាញតភ្ជាប់គ្នារបស់វានិងការរៀបចំជាទូទៅនៃប្រព័ន្ធធារាសាស្ត្រក្នុងឧទ្យានអង្គររួមមានស្ទឹង បារាយណ៍ កសិន្ធុទឹក អូរ អាងទឹក និងប្រឡាយតូចធំផ្សេងៗ។ ការសិក្សាស្រាវជ្រាវនៅនឹងទីកន្លែងផ្ទាល់បានបង្ហាញថាផ្នែកខាងជើងឈៀងខាងកើតនៃបារាយណ៍ខាងជើងមានទំនប់មួយដែលគេសង់ក្នុងទិសពីកើតទៅលិចនិងមានស្ពានបុរាណមួយធ្វើពីថ្មបាយក្រៀម នៅខាងក្រោមស្ពានមានប្រឡោះបង្ហូរទឹកជាច្រើនឆ្ពោះទៅស្ទឹងសៀមរាបដែលអាចប្រើប្រាស់សម្រាប់គ្រប់គ្រងជារទឹក និងលំហូរទឹក។ ដោយសារប្រព័ន្ធចែកចាយនិងអូរប្រទាក់ក្រឡាជាច្រើននេះហើយដែលយើងអាចបង្វែរទឹកសំដៅទៅទិសខាងលិច(មានបារាយណ៍ខាងជើងបារាយណ៍ខាងលិចនិងស្ទឹងពួក) សំដៅទៅទិសខាងកើត(មានស្ទឹងរលួស) និងសំដៅទៅទិសខាងត្បូង (មានកសិន្ធុទឹកអង្គរធំ អង្គរវត្ត និងស្ទឹងសៀមរាប)។ នៅឆ្នាំ២០១២ ផ្នែកសំខាន់នៃប្រព័ន្ធនេះត្រូវស្តារឡើងវិញ និងអនុញ្ញាតអោយឧទ្យានអង្គរ និងស្ទឹងសៀមរាបអាចជៀសផុតពីទឹកជំនន់ក្នុងរដូវវស្សា។ បើគ្មានការងារនេះទេ ក្រុងសៀមរាបប្រហែលជាបានទទួលរងគ្រោះដោយ ទឹកជំនន់យ៉ាងតិចចំនួនបួនរដូវជាប់ៗគ្នា។ លទ្ធផលនេះបញ្ជាក់ថា ប្រព័ន្ធធារាសាស្ត្របុរាណក្នុងសម័យអង្គរមិនត្រឹមតែអាច គ្រប់គ្រងបានយ៉ាងល្អនូវធនធានទឹកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចគ្រប់គ្រងទឹកជំនន់បានទៀតផង។

យើងជឿជាក់ថា នៅក្នុងសម័យអង្គរដ៏រុងរឿង រាជបុរីមួយនេះប្រាកដជាមានប្រព័ន្ធធារាសាស្ត្រដ៏មានប្រសិទ្ធភាពស៊ីសង្វាក់គ្នា និង ស្វ័យប្រវត្តិ។



អាងទទួលទឹកទាំងបីពីភ្នំគូលែន៖ ស្ទឹងពួក ស្ទឹងសៀមរាប និងស្ទឹងរលួស( ពីឆ្វេងទៅស្តាំ)



ប្រព័ន្ធធារាសាស្ត្រសម័យបុរាណក្នុងឧទ្យានអង្គរ

## ត្រឡប់ទៅអនាគតកាល

នៅពេលបច្ចុប្បន្ននេះ បារាយណ៍ខាងលិច ( មានសមត្ថភាពផ្ទុកទឹក៥៦លានម៉ែត្រគូប) បារាយណ៍ខាងត្បូង (មានសមត្ថភាពផ្ទុក ទឹក៥លានម៉ែត្រគូប) កសិន្ធុទឹកអង្គរធំ( មានសមត្ថភាពផ្ទុកទឹក២លានម៉ែត្រគូប) កសិន្ធុអង្គរវត្ត( មានសមត្ថភាពផ្ទុកទឹកជាង ១លានម៉ែត្រគូប) ទាំងអស់អាចផ្ទុកទឹកបានជាង៦៥លានម៉ែត្រគូបទៅហើយ។ក្នុងពេលទឹកជំនន់ឆ្នាំ២០១២អាងផ្ទុកទឹកទាំង នេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការស្រូបយកទឹកជាបណ្ដោះអាសន្ន ជួយសម្រួលក្នុងការគ្រប់គ្រងទឹកជំនន់។អាជ្ញាធរអប្សរា គ្រោងនឹងស្ដារបារាយណ៍ខាងកើតឡើងវិញ( មានសមត្ថភាពផ្ទុកទឹក៣៦លានម៉ែត្រគូប) និងបារាយណ៍លលៃ( មានសមត្ថភាពផ្ទុកទឹក១០លានម៉ែត្រគូប) ដែលនៅក្នុងពេលបច្ចុប្បន្ននេះបារាយណ៍ទាំងពីរបានរីងស្ងួតទាំងស្រុង។ បើបារាយណ៍ទាំងពីរនេះត្រូវ បានជួសជុលឡើងវិញ នោះសមត្ថភាពផ្ទុកទឹកសរុបទាំងអស់នឹងកើនដល់ប្រមាណ១១១លានម៉ែត្រគូប និងធានាបាននូវការ គ្រប់គ្រងទឹកជារួម និងការពារកុំអោយមានទឹកជំនន់នៅក្នុងតំបន់អង្គរ។

ចាប់ពីពេលនេះតទៅ យើងពិតជាយល់ច្បាស់អំពីប្រព័ន្ធធារាសាស្ត្រអង្គរ ហើយយើងបានរកឃើញផ្លូវនិងអាងទឹកជាច្រើននៅតាមទីកន្លែងផ្ទាល់។ការងារផ្សេងៗទៀតក៏ចាំបាច់ត្រូវធ្វើដែរ ដើម្បីជួសជុលប្រព័ន្ធទាំងមូលនេះឡើងវិញ និងធានាបាននូវចីរភាព នៃការថែទាំរបស់វា។

កម្មវិធីនេះគឺជាគំរូមួយនៃការអភិរក្ស និងការស្ដារឡើងវិញ។ ទំនើបកម្មនៃប្រព័ន្ធធារាសាស្ត្រអង្គរហាក់ដូចជាវិធីសាស្ត្រមួយដែលមានប្រសិទ្ធភាពនិងទទួលផលចំណេញជាងគេបំផុតក្នុងការចូលរួមប្រកបដោយនិរន្តរភាពក្នុងការអភិវឌ្ឍតំបន់អង្គរសៀមរាប និង កាត់បន្ថយភាពក្រីក្រ។

# ប្រព័ន្ធធារាសាស្ត្រនៃប្រាសាទព្រះវិហារ

*ហង់ ពៅ*
*អគ្គនាយកអាជ្ញាធរជាតិអប្សរា*

*ប្រាសាទព្រះវិហារស្ថិតនៅលើកំពូលជួរភ្នំដងរែកខាងជើងប្រទេសកម្ពុជា។ ឧទ្ទិសដល់ព្រះសិវៈ ប្រាសាទនេះត្រូវបានកសាងឡើងពីសតវត្សទី៩ដល់សតវត្សទី១២ សំខាន់គឺនៅសម័យសោយរាជ្យនៃស្តេចខ្មែរព្រះនាមសូរ្យវរ្ម័នទី១ ( ពីឆ្នាំ១០០២ ដល់ឆ្នាំ ១០៥០) និងព្រះបាទសូរ្យវរ្ម័នទី២ ( ពីឆ្នាំ ១១១៣ ដល់ឆ្នាំ១១៥០)។ ប្រាសាទនេះត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅឆ្នាំ ២០០៨ និងស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិសម្រាប់ការពារប្រាសាទព្រះវិហារដែលហៅកាត់ថា NAPV ។ ព្រះវិហារត្រូវបានកសាងឡើងផ្ទាល់នៅលើស្រទាប់ផ្ទាំងថ្ម ផ្ទុយពីប្រាសាទខ្មែរផ្សេងទៀតនៅក្នុងតំបន់អង្គរឬនៅតាមតំបន់វាលទំនាបផ្សេងដែលប្រាសាទផ្សេងៗទាំងនោះត្រូវបានកសាងឡើងនៅលើស្រទាប់ខ្សាច់ ធ្វើឲ្យប្រាសាទមានទំនាក់ទំនងផ្ទាល់ទៅនឹងការផ្លាស់ប្តូរកម្រិតទឹកក្រោមដី ឬក៏កម្រិតផ្អែតនៃដីខ្សាច់។ប៉ុន្តែទឹកនៅតែជាបញ្ហាប្រឈមដ៏ធំបំផុតសម្រាប់ការគ្រប់គ្រងប្រាសាទព្រះវិហារនេះ ក៏ដូចជានៅតាមទីកន្លែងផ្សេងទៀតក្នុងពិភពលោកដែរ។ នៅក្នុងអត្ថបទនេះយើងនឹងនិយាយផ្តោតទៅលើប្រព័ន្ធគ្រប់គ្រងទឹក រួមទាំងការប្រើប្រាស់ទឹកនិងការ បង្ហូរទឹកចេញ។ តើក្នុងសម័យបុរាណបុព្វបុរសខ្មែរចាត់ទុកទឹកដូចម្តេចដែរបើប្រៀបធៀបទៅនឹងបេតិកភណ្ឌ ហើយតើពួកគាត់គ្រប់គ្រង ទឹកយ៉ាងដូចម្តេចដែរ។ ប្រព័ន្ធធារាសាស្ត្រសំខាន់ៗទាំពីរ ត្រូវបានក៏សាងឡើងសម្រាប់ប្រាសាទនេះកាលពីសម័យបុរាណនៅខាងលើកំពូលភ្នំ ( ជុំវិញប្រាសាទ ) និងមួយទៀតនៅឯជើងភ្នំ ( នៅលើដីទំនាប )។*

## អាងផ្ទុកទឹកនិងប្រព័ន្ធធារាសាស្ត្រ

*ប្រាសាទព្រះវិហារមិនត្រូវការទឹកដើម្បីរក្សាលំនឹងឬដើម្បីជាការលម្អរបស់ខ្លួនឡើយ ប៉ុន្តែសម្រាប់ការគ្រប់គ្រងប្រាសាទនិងសម្រាប់អ្នកមកទស្សនាប្រាសាទនេះ។ ដោយសារថា ប្រាសាទនេះត្រូវបានកសាង*



កម្រិតទឹកនៅខែវិច្ឆិកា ក្នុងអាងទី៥



សំណឹករិចរឹលនៅចន្លោះអាងទី១ និងគោបុរៈទី២

ឡើងនៅលើកំពូលដែលខ្ពស់ជាងគេនៃជួរភ្នំនេះដូច្នេះគ្មានប្រភពទឹកណាមួយដែលអាចហូរទៅដល់សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃឡើយ។

ដើម្បីដោះស្រាយបញ្ហានេះ អាងទឹកចំនួន៦ត្រូវបានគេក៏សាងឡើងដើម្បីត្រងយកទឹកក្នុងរដូវវស្សា ហើយអាងទាំង៦នោះត្រូវបានឲ្យឈ្មោះទៅតាមទិសដៅនៃទឹកហូរពីខ្ពស់( ខាងត្បូង) ទៅទាប( ខាងជើង )។ អាងទឹកទាំងអស់មានលក្ខណៈដូចៗគ្នា៖ បាតក្រោមជាប់ នឹងស្រទាប់ផ្ទាំងថ្ម រីឯជញ្ជាំងធ្វើពីដីដែលគេបង្ហាប់យ៉ាងណែន ហើយអាងទាំងអស់មានក្រាលដោយថ្មភក់ដើម្បីការពារកុំឲ្យសឹកដី និងអនុញ្ញាតឲ្យអ្នកប្រើប្រាស់ដឹងពីកម្រិតទឹកដែលនៅសល់ក្នុងអាង ហើយអាចចុះទៅដងទឹកមកប្រើប្រាស់បានពីកន្លែងណាក៏បាន។ គេអាចគិតថាជម្រាបទឹកពីលើទៅក្រោម គឺគ្មានទាល់តែសោះពីព្រោះអាងទាំងនេះត្រូវបានកសាងឡើងដោយមានបាតជាប់នឹងស្រទាប់ផ្ទាំងថ្មផ្ទាល់តែម្តង។ដូច្នេះការបាត់បង់ទឹកនៅក្នុងអាងសំខាន់គឺបណ្តាលមកពីជម្រាបទឹកនៅតាមទិសបណ្តោយពីព្រោះជញ្ជាំងអាងគ្មានការថែទាំអស់រយៈពេលជាច្រើនឆ្នាំមកហើយបណ្តាលមកពីសង្គ្រាមអស់ជាច្រើនសតវត្ស និងដោយសារប្រព័ន្ធបង្ហូរទឹកមិនធ្លាប់ត្រូវបានជួសជុលឬថែទាំឡើយ។

ក្រៅពីមុខងារឆ្លើយតបទៅនឹងតម្រូវការទឹកប្រចាំថ្ងៃអាងទាំងនេះក៏មានប្រយោជន៍សម្រាប់កាត់បន្ថយលំហូរទឹកភ្លៀងនៅក្នុងប្រាសាទផងដែរ ដើម្បីកុំឲ្យមានសំណឹកនិងជះឥទ្ធិពលទៅលើលំនឹងរបស់ប្រាសាទ។ ប៉ុន្តែដោយសារមូលហេតុដែលថា ប្រព័ន្ធបង្ហូរទឹកនេះបានខូចខាតអស់ទៅហើយនោះ ទឹកភ្លៀងក៏ហូរពាសវាលពាសកាលដោយគ្មានការគ្រប់គ្រងត្រឹមត្រូវ។ដូច្នេះ ផ្នែកខ្លះនៃប្រាសាទក៏បានបាក់បែក ខូចខាត ហើយផ្នែកខ្លះទៀតក៏ទ្រេត ទ្រុឌទ្រោម ហើយផ្នែកទាំងនោះនឹងដួលរលំដូចគ្នាប្រសិនបើបញ្ហានេះមិនត្រូវបានដោះស្រាយជាបន្ទាន់នោះទេ។

ប្រាសាទព្រះវិហារមានគោបុរៈចំនួន៥ ហើយគោបុរៈទាំងនោះត្រូវបានឲ្យឈ្មោះពីទីកន្លែងខ្ពស់( នៅខាងត្បូង ) ទៅកន្លែងទាប ( នៅ ខាងជើង) ដូចគ្នាដែរ។

នៅក្នុងគោបុរៈទី១តួប៉មកណ្តាលបានបាក់បែកធ្លាក់ ហើយរោងទងខាងត្បូងឈៀងខាងកើតក៏ខូចខាតទាំងស្រុងដែរ ដោយសារប្រព័ន្ធបង្ហូរទឹកបុរាណបានស្ទះហើយទឹកភ្លៀងអាចអស់ពីកន្លែងនេះបានតាមតែចម្រោះឬសម្ងួតតែប៉ុណ្ណោះ។ផ្នែកខ្លះនៃអូរបង្ហូរទឹកចេញ គេអាចមើលឃើញនៅឡើយ ប៉ុន្តែភាគច្រើននៃអូរទាំងនោះគឺមានដីកកពេញអស់ទៅហើយ។ អាជ្ញាធរជាតិព្រះវិហារកំពុងខិតខំដោះស្រាយ បញ្ហានេះ។

អាងទី១នៅខាងកើតគោបុរៈទី២ មានប្រយោជន៍សម្រាប់ផ្ទុកទឹកភ្លៀងនិងទឹកដែលហូរពីតំបន់ខាងត្បូងមកនិងមួយផ្នែកធំពីគោបុរៈទី១។ អាងនេះមើលទៅដូចជាត្រូវបានកសាងឡើងក្រោយពីគេកសាងប្រាសាទរួច។ វាក៏អាចដែរថា អាងនេះត្រូវបានកសាងឡើង ដោយសង់ជញ្ជាំងបន្ថែមឲ្យខ្ពស់ដើម្បីពង្រីកសមត្ថភាពផ្ទុកទឹក ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការទឹកសម្រាប់ការគ្រប់គ្រងប្រាសាទ។ ក្រោយមក គេឃើញមានការចាក់ដីបន្ថែម ដើម្បីបង្កើតជាជម្រាលមួយរវាងអាងនិងប្រាសាទ។ប៉ុន្តែដំណោះស្រាយនេះមិនគ្រប់គ្រាន់ឡើយសម្រាប់បង្ហូរទឹកភ្លៀងចេញឲ្យអស់ហើយការដក់ទឹកនៅតាមគ្រឹះបានធ្វើឲ្យដីនៅខាងក្រោមរំកិលអស់ជាច្រើនសង់ទីម៉ែត្រ និង បណ្តាលឲ្យផ្នែកខាងលើនៃប្រាសាទបាក់ធ្លាក់ចុះមក។

អាងទី២នៅខាងជើងនៃអាងទី១មានប្រយោជន៍សម្រាប់ត្រងទឹកភ្លៀង និងទឹកដែលនៅសល់ពីអាងទី១ ព្រមទាំងសម្រាប់កាត់បន្ថយកម្លាំងជារទឹកដែលហូរសំដៅទៅបណ្ណាល័យនៃគោបុរៈទី៣។ដោយសារគ្មានការជួសជុលឬថែទាំអស់រយៈពេលជាច្រើននោះ អាចម៍ដី ដែលហូរពីខាងលើមកក៏បណ្តាលឲ្យមានទឹកច្រើនត្រូវដក់នៅខាងមុខបណ្ណាល័យខាងលិច និងខាងកើត។ ទឹកដក់នេះក៏ជ្រាបចូលទៅ ខាងក្រោមដីហើយបណ្តាលឲ្យបណ្ណាល័យត្រូវទ្រេត។

អាងទី៣មានប្រយោជន៍សម្រាប់ត្រងទឹកភ្លៀងនិងទឹកហូរមកពីខាងកើតនៃគោបុរៈទី៣។ ទឹកដែលហូរមកពីខាងលិចនៃគោបុរៈទី៣ពីមុន ហូរតាមបណ្តោយស្ពានហាលធំនិងតាមដីដែលមានដុះស្មៅ ប៉ុន្តែផ្លូវទឹកហូរនេះត្រូវបានស្ទះដោយសំណង់ចំណាតឧត្តម្កាចក្រ។នៅពេលបច្ចុប្បន្នផ្លូវហូរទឹកនេះត្រូវបានពង្វៀងនិងឆ្លងកាត់ស្ពានហាលធំនៅជិតគោបុរៈទី៤ ដើម្បីបង្ហូរទឹកបញ្ចូលទៅក្នុងអាងទី៥។ ដោយសារមូលហេតុនេះអាងនេះមានទឹកច្រើនជាងអាងផ្សេងទៀតនៅរដូវវស្សា ប៉ុន្តែមិនអាចរក្សាទឹកបានយូរទេដោយសាររំហួត។ ភាគច្រើននៃទឹកដែលហូរមកពីទិសខាងកើតបានទៅដល់អាងទី៣ ហើយទឹកដែលនៅសល់ទាំងប៉ុន្មានក៏ហូរទៅតាមបណ្តោយស្ពានហាលធំរហូតដល់អាងទី៥។ មានតែទឹកមួយផ្នែកតូចដែលហូរមកពីអាងទី៣ត្រង់ជ្រុងខាងជើង និងទឹកភ្លៀងតែប៉ុណ្ណោះដែលអាចបំពេញអាងទី៤។

អាងទី៦ នៅខាងជើងឈៀងខាងលិចគោបុរៈទី៥ គឺជាអាងដែលធំជាងគេនៅប្រាសាទព្រះវិហារ។ វាមានប្រយោជន៍សម្រាប់ទទួលផ្ទុកទឹកដែលហូរមកពីប៉ែកខាងលិចចន្លោះគោបុរៈទី៤និងគោបុរៈទី៥។ដើម្បីត្រងយកទឹកភ្លៀងដែលហូរមកនេះវិស្វករខ្មែរសម័យបុរាណបានកសាងកូនទំនប់ទឹកមួយធ្វើពីថ្មភក់ភ្ជាប់ទៅនឹងកូនអូរតូចមួយដើម្បីប្តូរទិសនៃទឹកហូរ បង្វែរទឹកដែលហូរកាត់តាមទំនប់នេះ ឲ្យសំដៅទៅអាងទី៦វិញ។ អូរទឹកនៅតាមបណ្តោយទំនប់នេះមានកន្លែងខ្លះត្រូវបានដាក់សន្ទះទប់ល្បឿននៃជារទឹក និងត្រងយកកំណកដីដែលហូរពីខាងលើមក ព្រមទាំងការពារអាងទី៦កុំឲ្យមានកំណកដីហូរចូល និងអនុញ្ញាតឲ្យទឹកហូរ ហើយផាត់កំណកដីចេញ។ ទំនប់នេះត្រូវបានគេហៅថាផ្លូវបុរាណដែរពីព្រោះគេប្រើវាជាផ្លូវឡើងទៅប្រាសាទពីទិសខាងលិច។ នៅក្នុងទសវត្សឆ្នាំ៨០ ដោយសារបរិមាណទឹកជាច្រើនបានហូរមកដល់ចំណុចនេះ អ្នកស្រុកដែលរស់នៅម្តុំនោះបានកសាងទំនប់បេតុងមួយភ្ជាប់ទៅនឹងអាងទី៦ ពង្រីកអាងនេះបួនប្រាំម៉ែត្រទៅក្រោមដើម្បីផ្ទុកទឹកឲ្យបានកាន់តែច្រើន ជាជាងជួសជុលអាងទឹកបុរាណ។

អាងផ្ទុកទឹកថ្មីមួយទៀតនៅជិតវត្តកែវសិខាគីរីស្វរៈត្រូវបានកសាងឡើងកាលពីថ្មីៗនេះដោយអ្នកស្រុកដើម្បីទទួលទឹកដែលហូរ មកពីជ្រុងខាងត្បូងឈៀងខាងលិចនៃប្រាសាទ។ ទិសនៃលំហូរទឹកចូលក្នុងអាងនេះមានបង្ហាញជូននៅក្នុងរូបភាព ( សូមមើលរូបភាព) ។ អាងផ្ទុកទឹកនេះ ដោយសារមានដើមឈើដុះពេញនៅខាងក្នុង អាចរក្សាទឹកបានយូរជាងអាងផ្សេងទៀតនៅក្នុងតំបន់នេះ។



រូបភាពកាត់ទទឹងនៃអាងបុរាណ




ប្រព័ន្ធបង្ហូរទឹកនៅក្នុងគោបុរៈទី១



ទិសដៅទឹកហូរអាងទឹកទី១ អាងទី២និងកន្លែងនៃសំណឹក



ទិសដៅទឹកហូរអាងទឹកទ៣ អាងទី៤និងអាងទី៥



អាងទី៥និងទិសដៅទឹកហូរ

## ប្រព័ន្ធទាយរាយណ៍

កាលពីពេលថ្មីៗនេះ បារាយណ៍ពីរត្រូវបានគេរកឃើញនៅជិតរមណីដ្ឋានប្រាសាទព្រះវិហារនៅជើងភ្នំតែម្តង។ បារាយណ៍មួយនៅខាងលិច មួយទៀតនៅខាងកើតតាមបណ្តោយទិសប្រាសាទ ដែលគេហៅថា បារាយណ៍ខាងលិចនិងបារាយណ៍ខាងកើត។បារាយណ៍ ទាំងពីរមានទឹកហូរបំពេញដោយកូនអូរដែលហូរធ្លាក់ពីលើភ្នំមក។របកគំហើញនេះអាចធ្វើឲ្យយើងធ្វើការសន្និដ្ឋានថាប្រាសាទព្រះវិហារប្រហែលជាត្រូវទទួលមនុស្សជាច្រើនដែលធ្វើដំណើរមកពីទូទាំងប្រទេស ជាពិសេសអ្នកធ្វើធម្មយាត្រាមកបន់ស្រន់ឬក៏គោរពចំពោះ ប្រាសាទនេះ។

បារាយណ៍ខាងលិចនៅជិតផ្លូវឡើងទៅលើកំពូលភ្នំ នៅខាងលិចគោបុរៈទី៥។ ទឹកដែលហូរមកដល់ដំបូងគឺនៅជិតជ្រុងខាងជើងឈៀង ខាងកើត ដូចដែលមានចង្អុរបង្ហាញស្រាប់តាមរយៈវត្តមានថ្មបាយក្រៀមមួយដុំដែលបុរាណវិទូរបស់អាជ្ញាធរជាតិព្រះវិហារបានរកឃើញ។ដូចសព្វមួយដងដែរ នៅក្នុងសម័យបុរាណ ចំនុចដែលទឹកហូរមកដល់គឺនៅត្រង់កន្លែងខ្ពស់ជាងគេនៃបារាយណ៍ដើម្បីប្រមូល និងផ្ទុកទឹកឲ្យបានច្រើនបំផុតដែលអាចធ្វើទៅបាន។



អាងទី៣និងទេសភាពជុំវិញ

## រូបអាងដីឥដ្ឋនិងទេសភាពជុំវិញ

អាជ្ញាធរជាតិព្រះវិហារបានស្តារបារាយណ៍ខាងលិចឡើងវិញនៅខែមិនាឆ្នាំ២០១១ដោយបានសម្អាតកំណាកដីនៅបាតអាងនិងបានលើកទំនប់មួយដើម្បីបង្វែរទឹកបញ្ចូល។ដើម្បីបង្វែរទឹកបញ្ចូលបំពេញបារាយណ៍ខាងលិចគេគួរតែអាចប្រើប្រាស់ទឹកដែលហូរយ៉ាងច្រើនមកពីផ្នែកខាងជើងឈៀងខាងកើតនៃបារាយណ៍។ ដើម្បីកសាងបាននៅប្រព័ន្ធធារាសាស្ត្របែបនេះគេត្រូវសង្កេតអស់រយៈពេលជាច្រើនឆ្នាំលើទឹកភ្លៀងនិងលំហូរទឹក ( កម្រិតទឹកនិងទិសដៅទឹកហូរ) ដើម្បីធ្វើសម្រង់ទិន្នន័យអំពីទឹក។ ការចុះទៅពិនិត្យនៅប្រាសាទផ្ទាល់បានអនុញ្ញាតឲ្យយើងធ្វើសេចក្តីសន្និដ្ឋានថាកូនអូរតូចៗទាំងនេះហូរតែរដូវវស្សាប៉ុណ្ណោះ។បច្ចុប្បន្ននេះអាជ្ញាធរជាតិព្រះវិហារប្រើកូន អូរតូចៗពីរដែលមានទឹកហូរឆ្លងកាត់ក្រោមស្ពាននៅតាមផ្លូវចាក់បេតុងឡើងទៅប្រាសាទ។ ដោយសារយើងមិនទាន់មានទិន្នន័យទឹក និង ឧតុនិយមអំពីប្រាសាទនៅក្នុងដៃ វាពិតជាមានការលំបាកក្នុងការពិពណ៌នាអំពីប្រតិកម្មរូបវ័ន្តនៃអាងផ្ទុកទឹករបស់កូនអូរតូចៗទាំងពីរនេះ ដែលលំហូរទឹកប្រែប្រួលទៅតាមកម្លាំងនៃទឹកភ្លៀង។

ការសិក្សាឋានលេខាបង្ហាញថា បារាយណ៍ខាងលិខមិនសូវជ្រៅដែលអាចផ្ទុកទឹកឲ្យបានពេញមួយឆ្នាំនោះទេ។ បន្ទាប់ពីធ្វើការសិក្សា បុរាណវិទ្យារួចមក វានៅលំបាកក្នុងការកំណត់ថា ពេលណាដែលបារាយណ៍រីងស្ងួតទាំងស្រុង តើបារាយណ៍នោះមានទឹកពេញដោយរបៀបណា។ ជម្រៅរបស់វានៅពេលបច្ចុប្បន្ននេះប្រែប្រួលប្រមាណ២ម៉ែត្រពីជ្រុងខាងជើងឈៀងខាងកើតដែលខ្ពស់ជាងគេ ទៅជ្រុងដែលទាបជាងគេនៅខាងត្បូងឈៀងខាងលិច។ ដូច្នេះ យោងតាមស្ថានភាពជាក់ស្តែងនិងលក្ខខណ្ឌបរិស្ថាន បរិមាណទឹក នៅសល់ក្នុងអាងពិតជាតិចជាងបរិមាណទឹកដែលបាត់បង់ដោយរំហួតនិងដោយជម្រាប។



អាងទឹកទី៤និងតំបន់ជុំវិញ

បារាយណ៍ខាងលិចត្រូវបានកសាងឡើងដើម្បីផ្ទុកទឹកសម្រាប់ប្រើប្រាស់ប្រចាំឆ្នាំ។ អាចនិយាយម្យ៉ាងទៀតថាវាត្រូវមានទឹកហូរបំពេញជាប់ជានិច្ច វាអាចជាទឹកដែលជ្រាបចេញពីទឹកក្រោមដីនៅជិតនោះ ឬមានប្រភពទឹកមួយឬច្រើន( ទឹកនៅតែហូរនៅរដូវប្រាំង)។ កត្តាទាំងអស់នេះប្រហែលជាពឹងផ្អែកទៅលើព្រៃឈើនៅតំបន់ដែលបង្កឲ្យមានសំណើម និងកាត់បន្ថយរំហួតទឹកនិងជម្រាបកាន់តែខ្លាំងទៅក្នុងដី បណ្តាលឲ្យកម្រិតទឹកក្រោមដីខ្ពស់ និងជ្រាបកាន់តែខ្លាំងទៅលើផ្ទៃដីខាងលើវិញនិងកាត់បន្ថយការបាត់បង់ទឹកក្នុងបារាយណ៍។ បារាយណ៍ខាងកើតនៅជិតជណ្តើរខាងកើត ដែលគេប្រើក្នុងសម័យបុរាណ បារាយណ៍នេះនៅជិតមជ្ឈមណ្ឌលបដិសណ្ឋារកិច្ចដែល អាជ្ញាធរជាតិព្រះវិហារទើបបានកសាងឡើងកាលពីពេលថ្មីៗនេះ។ យើងប្រហែលជាអាចបង្វែរទឹកចូលក្នុងបារាយណ៍ឲ្យមានទឹកសារជាថ្មីឡើងវិញ តាមកូនអូរជិតនោះ ដោយឆ្លងកាត់តាមទ្វារទឹកបុរាណត្រង់ជ្រុងខាងជើងឈៀងខាងលិច។

## អនុសាសន៍សម្រាប់ការជំរុញការអភិវឌ្ឍន៍

ដោយសារមូលហេតុនៃកាផ្លាស់ប្តូរអាកាសធាតុនិងការរៀបចំដីធ្លី វាជាកាចាំបាច់ដែលត្រូវធ្វើការគ្រប់គ្រងរួមនៃធនធានទឹកសម្រាប់រមណីដ្ឋានប្រាសាទព្រះវិហារដោយគិតគូរដល់អនុសាសន៍ខ្លះៗដូចខាងក្រោមនេះ ៖

- ត្រូវសាងសង់ស្ថានីយ៍ឧតុនិយមមួយនៅនឹងរមណីដ្ឋាន
- ត្រូវធ្វើការសិក្សាស្រាវជ្រាវអំពីទិសដៅទឹកហូរ និងប្រភពទឹកដែលហូរមកចូលក្នុងអាងនិងបារាយណ៍ទាំងអស់នៅរដូវវស្សា
- ដើម្បីធានាថា ប្រភពទឹកទាំងអស់ហូរបំពេញបារាយណ៍ គេចាំបាច់ត្រូវការពារព្រៃឈើ និងដាំដើមឈើឡើងវិញនៅក្នុងតំបន់ទាំងមូល។ ព្រៃឈើអាចដើរតួនាទីមិនត្រឹមតែបង្កើតឡើងវិញនូវប្រភពទឹកនៅក្នុងតំបន់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចូលរួមដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃអេកូទេសចរណ៍ទៀតផង។

ការសិក្សាស្រាវជ្រាវពីប្រព័ន្ធធារាសាស្ត្រនៅប្រាសាទព្រះវិហាបង្ហាញថា បុព្វបុរសខ្មែរពិតជាបានយល់យ៉ាងច្បាស់ពីសារៈសំខាន់នៃទឹក ហើយថាត្រូវគ្រប់គ្រងវាដោយរបៀបណា។ អាងទឹកនិងបារាយណ៍មិនមែនត្រូវបានគេកសាងឡើងដើម្បីជាការរៀបចំទេសភាពលម្អប្រាសាទនោះឡើយ។ ទេវាក៏មិនត្រូវបានគេសាងឡើងក្នុងគោលបំណងរក្សាលំនឹងប្រាសាទដូចនៅអង្គរឬនៅតំបន់វាលទំនាបផ្សេងទៀតនោះដែរ។ផ្ទុយទៅវិញអាងទឹកនិងបារាយណ៍ទាំងនោះត្រូវបានគេកសាងឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រចាំថ្ងៃរបស់ប្រជាជនដែលរស់នៅក្នុងរមណីដ្ឋាននេះ (អ្នកស្រុកនិងភ្ញៀវដែលមកពីក្រៅ)។ យើងខ្ញុំសង្ឃឹមថា អាងទឹកនិងបារាយណ៍ទាំងអស់នឹងអាចត្រូវបានជួសជុលឡើងវិញ ដើម្បីឲ្យវាដើរតួនាទីសារជាថ្មីនៅក្នុងរមណីដ្ឋាននេះដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ហើយដែលកំពុងចាប់ផ្តើមទាក់ទាញភ្ញៀវទេសចរកាន់តែច្រើនឡើងៗ។

អាជ្ញាធរអប្សរា
APSARA

អាជ្ញាធរជាតិអប្សរា
APSARA National Authority

9 789924 939405 >